ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# បនដ្ឋានអនុវត្តបច្ចេកវិទ្យា

# ការផលិតកូនត្រីទីឡាព្យ៉ាក្នុងស្រះជាលក្ខណៈគ្រួសារ





រៀបចំដោយ នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម

សហការជាមួយ រដ្ឋបាលជលផល

?? ត្ថម្ភដោយ ? គម្រោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី



**រៀបរៀងដោយៈ លោក ជិន ដា**

**រដ្ឋបាលជលផល**

ទូរស័ព្ទលេខៈ ០២៣ ៩៩៦ ៣៨០ ឬ ០១១៩៩០៩៩០

អ៊ីម៉ែលៈ smallfish@online.com.kh

**កាលបរិច្ឆេទៈ ខែ តុលា ២០០៦**

© រក្សាសិទ្ធិគ្រប់យ៉ាងៈ គ្រប់បទដ្ឋានអនុវត្តបច្ចេកវិទ្យា (បអប) ទាំងអស់រួមទាំងឯកសារនេះជាកម្មសិទ្ធិរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ហើយសំរេចផ្តល់អោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មធ្វើជាម្ចាស់កម្មសិទ្ធិ ។ រាល់សំណើសុំផលិតបន្ថែមត្រូវសុំការអនុញ្ញាតសិទ្ធិជាមុន ពីនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។

# បុព្វកថា

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រោមកិច្ចសហការគាំទ្រពីទីភ្នាក់ងារអូស្ត្រាលីសំរាប់ការអភិវឌ្ឍន៍ អន្តរជាតិ (AusAID)តាមរយៈគំរោងការផ្សព្វផ្សាយកសិកម្ម កម្ពុជា-អូស្ត្រាលី ជំហានទី២ (២០០១-២០០៦) ដែលមានគោលដៅពង្រឹង ស្ថាប័ន និងប្រព័ន្ធផ្សព្វផ្សាយកសិកម្មនៅកម្ពុជា បានខិតខំយ៉ាងពេញទំហឹងដើម្បីធ្វើការពង្រឹងសមត្ថភាពមន្ត្រីផ្សព្វផ្សាយកសិកម្ម ការរៀបចំកសាងផែនការផ្សព្វផ្សាយកសិកម្មស្របតាមគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល តាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ សង្កាត់ និងបានចងក្រងជាបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះឡើង។

បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ បានចងក្រងដោយអ្នកជំនាញឯកទេស (Suject Matter Specialist) នឹងត្រូវបានឆ្លងការពិនិត្យ ពិគ្រោះយោបល់ និងឯកភាពយល់ព្រមពីគណៈកម្មការបច្ចេកទេសដែលមានសមាសភាពមកពីនាយកដ្ឋាន ជំនាញនានានៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ និងអ្នកពាក់ពន្ធ័ផ្សេងៗទៀត។ ឯកសារដ៏មានសារៈសំខាន់នេះ គឺជាឯកសារគោលដែលពិពណ៌នាអំពី ព័ត៌មានបច្ចេកទេស វិធីសាស្ត្រ នីតិវិធី និងផែនការថវិកាចំណាយសម្រាប់ជួយដល់មន្ត្រីកសិកម្មស្រុក និងភ្នាក់ងារប្រតិបត្តិនៅមូលដ្ឋាននានាយកទៅប្រើប្រាស់ក្នុងការបណ្តុះបណ្តាល និងផ្សព្វផ្សាយបច្ចេកទេសថ្មីៗ ក្នុងបំណងផ្ទេរចំណេះដឹងព័ត៌មាន និងបច្ចេកវិទ្យាកសិកម្មតាមគ្រប់រូបភាពឱ្យបានជ្រួតជ្រាបដល់ប្រជាកសិករ និងផលិតករ ដែលរស់នៅក្នុងតំបន់មានសក្តានុពលភាពស្របតាមលក្ខខណ្ឌភូមិសាស្ត្រ សេដ្ឋកិច្ចសង្គម និងតម្រូវការចាំបាច់ជាក់លាក់នៅ មូលដ្ឋាន ។

ដូច្នេះបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ មានសារៈប្រយោជន៍ជារួមសម្រាប់មន្ត្រីកសិកម្មខេត្ត-ក្រុង យកទៅប្រើប្រាស់ក្នុងការចូលរួមដោះស្រាយបញ្ហាចំពោះមុខ ដែលប្រជាកសិករយើងកំពុងប្រឈមមុខនៅក្នុងការធ្វើផលិតកម្មកសិកម្ម ពិពិធកម្មកសិកម្ម ដើម្បីធានាសន្តិសុខស្បៀង និងបង្កើនប្រាក់ចំណូលគ្រួសារ ជាពិសេសរួមចំណែកកាត់បន្ថយភាពក្រីក្រស្របតាមយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ។

ក្រសួងកសិកម្មម រុក្ខាប្រមាញ់ និងនេសាទ គាំទ្រនូវឯកសារបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដែលជាឯកសារគោលសម្រាប់មន្ត្រីកសិកម្មស្រុក ខេត្ត-ក្រុង អង្គការក្រៅរដ្ឋាភិបាល ភ្នាក់ងារប្រតិបត្តិនានានៅមូលដ្ឋាន និងអ្នកពាក់ព័ន្ធទាំងអស់យកទៅអនុវត្តក្នុងការផ្ទេរបច្ចេកវិទ្យាដល់ប្រជាកសិករនៅជនបទឱ្យទូលំទូលាយ និងទទួលបានផ្លែផ្កាល្អប្រសើរប្រកបដោយក្តីសង្ឃឹម។

**រដ្ឋមន្ត្រី**

# អារម្ភកថា

ពាក្យពេញនៃ **បអប** គឺ "បទដ្ឋានអនុវត្តបច្ចេកវិទ្យា" ។ បអប ពន្យល់ពីរបៀបអនុវត្តបច្ចេកវិទ្យា ដើម្បីជួយដោះស្រាយបញ្ហាផ្នែកកសិកម្មរបស់កសិករ។ បអប ផ្ទុកនូវព័ត៌មានបទដ្ឋាន និងសំភារៈសម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយផ្ទេរបច្ចេកវិទ្យានេះទៅកសិករ។ គោលគំនិតនៃបអប គឺដើម្បីផ្សព្វផ្សាយដល់ឃុំ ស្រុក និងខេត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប ត្រូវបានគេសរសេរសម្រាប់ឱ្យមន្ត្រីផ្សព្វផ្សាយ អង្គការក្រៅរដ្ឋាភិបាល និងផ្នែកផ្សេងៗទៀត ដែលបំរើការនៅក្នុងវិស័យអភិវឌ្ឍន៍កសិកម្មនៅតាមមូលដ្ឋានប្រើប្រាស់។ បអប មានលក្ខណៈដូចខាងក្រោមនេះ ៖

- អាចបត់បែនបាន-បអប អាចយកទៅអនុវត្តបាននៅគ្រប់ទីកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា
- សាមញ្ញ-បអប អាចប្រើប្រាស់បានដោយគ្រប់ផ្នែកដែលបំរើការនៅតាមមូលដ្ឋាន
- ងាយយល់-ងាយស្រួលក្នុងការផ្តល់នូវព័ត៌មានសំខាន់ៗ

បអប ត្រូវបានកំណត់អាទិភាពដោយផ្អែកទៅតាមបញ្ហាផ្នែកកសិកម្មសំខាន់ៗរបស់កសិករ តាមរយៈប្រភពជាច្រើនដូចជា ប្រព័ន្ធគ្រប់គ្រងព័ត៌មានរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម (FSMIS) ដែលផ្ទុកនូវព័ត៌មានសំខាន់ៗ របស់កសិករ។ បញ្ហាផ្នែកកសិកម្មរបស់កសិករ ត្រូវបានគេវិភាគតាមរយៈការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានថ្នាក់ឃុំ-សង្កាត់ (AEA) នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។ បអប មាននៅតាមស្ថាប័ន នានាដូចខាងក្រោម:

- វិទ្យាស្ថានស្រាវជ្រាវជាតិ
- ក្រុមកសិករ
- អង្គការក្រៅរដ្ឋាភិបាល
- ទីភ្នាក់ងារស្រាវជ្រាវអន្តរជាតិ
- កម្មវិធីផ្សព្វផ្សាយ
- ម្ចាស់ជំនួយ
- ផ្នែកឯកជន

បអប ត្រូវបានគ្រប់គ្រងដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បអប ត្រូវបានសរសេរដោយអ្នកឯកទេសដែលមានបទពិសោធន៍នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ដូច្នេះ បអប ផ្ទុកនូវបទពិសោធន៍ល្អៗសម្រាប់អនុវត្តបច្ចេកវិទ្យា។ បអប ត្រូវបានឆ្លងកាត់ការត្រួតពិនិត្យរបស់ក្រុមការងារ បអប បន្ទាប់មកអនុម័ត និងអនុញ្ញាតដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទសម្រាប់ប្រើប្រាស់នៅតាមមូលដ្ឋាន។

# មាតិកាអត្ថបទ


**១. សេចក្តីអត្ថាធិប្បាយ**

**២. គោលការណ៍បច្ចេកទេស**

២.១- ហេតុអ្វីយើងចាំបាច់ផលិតកូនត្រីពូជ ?

២.២- ការជ្រើសរើសទីកន្លែង សម្រាប់ការអភិវឌ្ឍន៍ផលិតកម្មកូនត្រីពូជ

២.២.១- លក្ខណៈប្រភពទឹក

២.២.២- លក្ខណៈតំបន់អភិវឌ្ឍន៍ផលិតកម្មកូនត្រីពូជ

២.២.៣-លក្ខណៈសេដ្ឋកិច្ចសង្គម

២.៣- ការជ្រើសរើសកសិករ សម្រាប់ផ្សព្វផ្សាយបច្ចេកទេសផលិតកូនត្រីពូជ

២.៤- លក្ខណៈជីវសាស្ត្រត្រីទីឡាព្យ៉ា

២.៥- របៀបជីកស្រះ សម្រាប់ផលិតកម្មកូនត្រីពូជទីឡាព្យ៉ា

២.៥.១- ការជ្រើសរើសទីតាំងជីកស្រះ

២.៥.២- គុណភាពដី សម្រាប់ស្រះចិញ្ចឹមត្រី

២.៥.៣-របៀបជីកស្រះចិញ្ចឹមត្រី

២.៦- ការរៀបចំស្រះ មុនពេលដាក់ត្រីមេពូជ

២.៦.១- ការស្តារភក់បាតស្រះ

២.៦.២- ការប្រើប្រាស់កំបោរ និងជី

២.៦.៣-ការត្រួតពិនិត្យគុណភាពទឹក

២.៧- ការជ្រើសរើសត្រីមេពូជដាក់បង្កាត់

២.៨- ការដឹកជញ្ជូនត្រីមេពូជ

២.៩- ការដាក់ត្រីមេពូជបង្កាត់ក្នុងស្រះ

២.៩.១- ការជ្រើសរើសត្រីមេពូជ

២.៩.២- ការដាក់បង្កាត់ត្រីមេពូជ

២.១០- ប្រភេទចំណី និងការផ្តល់ចំណី

២.១១- ប្រភេទជី និងការផ្តល់ជី

២.១២- ការគ្រប់គ្រងស្រះ

២.១២.១-ការត្រួតពិនិត្យគុណភាពទឹក

២.១២.២- ការការពារជម្ងឺ ក្នុងផលិតកម្មកូនត្រីពូជ

២.១២.៣- ការគ្រប់គ្រងស្រះបង្កាត់

២.១២.៤- ការគ្រប់គ្រងស្រះបំប៉នកូនត្រី

២.១៣- ការប្រមូលផលកូនត្រីពូជ

២.១៤- ការចាប់លក់កូនត្រីពូជ

២.១៥- ការគ្រប់គ្រងត្រីមេពូជ

២.១៦- ការវិភាគសេដ្ឋកិច្ច

**៣- វិធីសាស្ត្រផ្សព្វផ្សាយ**

៣.១- ការសិក្សាទីផ្សារ និងការធ្វើផែនការផលិតកម្មកូនត្រីពូជ

៣.២- ការផ្សព្វផ្សាយបច្ចេកទេស

៣.៣- ការចំណាយសម្រាប់ការធ្វើបង្ហាញ

៣.៤- ការចូលរួមរបស់ស្ត្រី ក្នុងសកម្មភាពវារីវប្បកម្ម

**៤- សេចក្តីបន្ថែម**

៤.១- បញ្ហាអាចកើតមានក្នុងពេលផលិតកូនត្រី និងវិធានការដោះស្រាយ

៤.២- តារាងប្រមូលទិន្នន័យ



## ១- សេចក្តីអធិប្បាយ

**សេចក្តីសង្ខេប**

**បញ្ហា** ទិន្នផលផលិតកម្មកូនត្រីពូជជាលក្ខណៈគ្រួសារ ទទួលបានបរិមាណតិចតួច

**គោលដៅ** បង្កើនទិន្នផលផលិតកម្មកូនត្រីពូជជាលក្ខណៈគ្រួសារ (៨.០០០- ១០.០០០) ក្បាល កូនត្រីទីឡាព្យ៉ា ក្នុងផ្ទៃស្រះ ១០០ម$^{២}$ រយៈពេល ៨ ខែ ។

**បច្ចេកទេសផលិត** ១- ការរៀបចំស្រះ មុនពេលដាក់ត្រីមេពូជ ឬកូនត្រី

២- ការជ្រើសរើសគុណភាពត្រីមេពូជ និងបច្ចេកទេសដឹកជញ្ជូន

៣- ការដាក់បង្កាត់ត្រីមេពូជក្នុងស្រះ

៤- ការថែបំប៉នត្រីមេពូជ និងកូនត្រីពូជ

៥- ការត្រួតពិនិត្យគុណភាពទឹកជាប្រចាំ ដើម្បីឱ្យសម្បូរចំណីធម្មជាតិក្នុងស្រះ សម្រាប់ត្រី

**អត្ថប្រយោជន៍**

- ❑ កាត់បន្ថយការចំណាយប្រាក់ទិញកូនត្រីពូជ សម្រាប់ដាក់ចិញ្ចឹមបន្តនៅឆ្នាំក្រោយ
- ❑ មិនបាច់ចំណាយពេលទៅរកទិញកូនត្រីទីឡាព្យ៉ា ដែលមានលក់នៅឆ្ងាយពីផ្ទះ
- ❑ បច្ចេកទេសផលិតកូនត្រីពូជទីឡាព្យ៉ាមានលក្ខណៈងាយស្រួលឱ្យកសិករ (អ្នកផ្សព្វផ្សាយ) ងាយយល់
- ❑ កសិករងាយយកទៅអនុវត្ត ទទួលបានជោគជ័យ
- ❑ កសិករអាចផលិតកូនត្រីទីឡាព្យ៉ាបានច្រើន សម្រាប់លក់ចែកដល់អ្នកចិញ្ចឹម
- ❑ កសិករអាចរកប្រាក់ចំណូលបានស្រួល ពីការផលិតកូនត្រីពូជទីឡាព្យ៉ា
- ❑ ប្រើប្រាស់ទុនចំណាយតិចតួច ក្នុងដំណើរការផលិត
- ❑ ត្រីទីឡាព្យ៉ាជាប្រភេទត្រី កសិករចូលចិត្តចិញ្ចឹម ព្រោះវាងាយស្រួលក្នុងការចិញ្ចឹម
- ❑ បង្កើនចំនួនកសិករចិញ្ចឹមត្រី ពីមួយឆ្នាំ ទៅមួយឆ្នាំ
- ❑ កាត់បន្ថយការចាប់ត្រីពីធម្មជាតិ ។

**លក្ខខណ្ឌអំណោយផលនៃបច្ចេកទេសផលិតកូនត្រី**

លក្ខណៈវិនិច្ឆ័យខាងក្រោមនេះ ជាលក្ខខណ្ឌចាំបាច់ក្នុងការអនុវត្តបទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ ដើម្បីសម្រេចបាននូវគោលដៅដែលបានរៀបរាប់ខាងលើ ៖

**លក្ខណៈអាកាសធាតុ និង ទឹកសម្រាប់ផលិតកូនត្រី**

- ❑ ស្រះទាំងអស់ក្នុងកសិដ្ឋាន ទាំងស្រះត្រីមេពូជ និងស្រះបំប៉នកូនត្រី ត្រូវមានទឹកគ្រប់គ្រាន់ពេញមួយរដូវ ដើម្បីរៀបចំដំណើរការផលិតកូនត្រីពូជឱ្យបានពេញមួយឆ្នាំ ។
- ❑ ស្រះទាំងអស់ត្រូវការពារកុំឱ្យលិចទឹកនៅរដូវវស្សា ដើម្បីការពារកុំឱ្យត្រីចិញ្ចឹមរួចចេញពីស្រះ និង ត្រីស្រែចូលស្រះ ។

- ❑ ម្យ៉ាងទៀត ស្រះចិញ្ចឹមត្រីចាំបាច់ត្រូវការពារកុំឱ្យមានប្រភពទឹកពុលចូលស្រះ ដូចជា ទឹកដែលមានប្រើថ្នាំគីមីពុល ឬ ថ្នាំសម្លាប់សត្វល្អិតជាដើម ។
- ❑ ជាទូទៅអាកាសធាតុនៅប្រទេសកម្ពុជា គឺមានលក្ខណៈអំណោយផលល្អ សម្រាប់ដំណើរការផលិតកម្មកូនត្រី ។

**លក្ខណៈភូមិសាស្ត្រ**

- ❑ ការផលិតកូនត្រីចាំបាច់ត្រូវយកចិត្តទុកដាក់អនុវត្តតាមលក្ខខណ្ឌ ដែលបានថែងខាងលើ
- ❑ ការអនុវត្តតាម " បទដ្ឋានអនុវត្តបច្ចេកវិទ្យា " នេះបានជោគជ័យក៏អាស្រ័យនឹងការជ្រើសរើសកសិករដែលមានសមត្ថភាពអនុវត្តបច្ចេកទេសដូចក្នុងសៀវភៅនេះ ។

**ទំហំកសិដ្ឋាន**

ទំហំផ្ទៃដីកសិដ្ឋានផលិតកូនត្រីកាន់តែធំ ចំនួនស្រះត្រីអាចជីកបានកាន់តែច្រើន ហើយបរិមាណកូនត្រីពូជក៏ផលិតបានកាន់តែច្រើនដែរ ។ ជាទូទៅ ស្រះចិញ្ចឹមត្រីនៅតាមជនបទ មានទំហំពី ៨០- ២០០ម² ស្រះត្រីមានទំហំតូចជាងនេះ ក៏អាចផលិតកូនត្រីពូជទីឡាព្យ៉ានេះបានដែរ ប៉ុន្តែបរិមាណផលកូនត្រីទទួលបានតិចតួច ។

**តម្រូវការកម្លាំងពលកម្ម**

- ❑ ការផលិតកូនត្រីទីឡាព្យ៉ាជាលក្ខណៈគ្រួសារ នៅតាមជនបទអាចអនុវត្តបានដោយប្រើប្រាស់កម្លាំងពលកម្មក្នុងគ្រួសារ ។
- ❑ ដូចជា ការរៀបចំស្រះ និងការដឹកជញ្ជូនកូនត្រីពូជ អនុវត្តដោយកម្លាំងបុរស
- ❑ ការលក់កូនត្រីពូជ និងត្រីសាច់ ជាធម្មតាស្ត្រីជាអ្នកអនុវត្ត
- ❑ សកម្មភាពអនុវត្តដទៃទៀតដូចជា ការជីកស្រះ ការបង្កាត់ភ្ញាស់ ការដាក់ត្រីចិញ្ចឹម ឬថែបំប៉នក្នុងស្រះ ការផ្តល់ចំណី និងជី ការត្រួតពិនិត្យមើលស្រះត្រី និងការប្រមូលផលត្រីច្រើនធ្វើឡើងដោយកម្លាំងពលកម្មរួមគ្នាដែលមានក្នុងគ្រួសារ ។

**ស្ថានភាពសេដ្ឋកិច្ចនៃការផលិតកូនត្រី របស់កសិករ**

ការផលិតកូនត្រីទីឡាព្យ៉ាជាលក្ខណៈគ្រួសារ កសិករអាចប្រើប្រាស់ទុន ៤០០.០០០៛ ក្នុងករណីកសិករមានស្រះត្រីមេពូជ និងស្រះបំប៉នហើយ។ ទុននេះសម្រាប់ចំណាយទៅលើ ការរៀបចំស្រះ ទិញត្រីមេពូជ ចំណី ជី អួនអួសត្រីមេពូជ ឬកូនត្រីពូជ និងទិញហាប៉ាសម្រាប់បំប៉នកូនត្រី។ ការចំណាយនេះនឹងអាចអនុវត្តសកម្មភាពផលិតកូនត្រីពូជ ទីឡាព្យ៉ាតាម (បទដ្ឋានអនុវត្តបច្ចេកវិទ្យា) នេះ ។

**សម្រាប់ព័តិមានបន្ថែមសូមទាក់ទង**

ការិយាល័យវារីវប្បកម្ម រដ្ឋបាលជលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
ទូរស័ព្ទលេខ: ០២៣ ៩៩៦ ៣៨០ ឬ អ៊ីម៉ែល: smallfish@online.com.kh

## ២- គោលការណ៍បច្ចេកទេស

### ២.១- ហេតុអ្វីយើងចាំបាច់ផលិតកូនត្រីពូជ ?

ប្រទេសកម្ពុជា ផលិតកម្មវារីវប្បកម្មបាន និងកំពុងចូលរួមវិភាគទានកាន់តែច្រើនឡើងដល់ផលិតកម្មត្រី

សរុបទូទាំងប្រទេស ។ គួរកត់សំគាល់ថា នៅឆ្នាំ ២០០៥ កន្លងមកនេះ ផលិតកម្មវារីវប្បកម្មទឹកសាបបានកើនដល់ ២៦.០០០ តោន ប្រហែលស្មើនឹង ៧% នៃផលិតកម្មត្រីសរុបទូទាំងប្រទេស ដែលមាន ៤១០.០០០ តោន។ បើប្រៀបធៀបទៅនឹងផលិតកម្មវារីវប្បកម្មនៅឆ្នាំ ១៩៨៤ គឺមានតែ ១.៦១០ តោន។ ដូចនេះ មានន័យថាផលិតកម្មវារីវប្បកម្ម បានកើនឡើងកាន់តែច្រើនឡើងពីមួយឆ្នាំ ទៅមួយឆ្នាំ ពិសេសរួមបញ្ចូលទាំងផលិតកម្មវារីវប្បកម្មជាលក្ខណៈគ្រួសារ ដែលមានសារៈសំខាន់បំផុតក្នុងការជួយកែលំអការចិញ្ចឹមជីវិតរបស់ប្រជាកសិករក្រីក្រ ។ បច្ចុប្បន្នមានប្រជាកសិករនៅតាមជនបទជាច្រើនគ្រួសារកំពុងចូលរួមសកម្មភាពវារីវប្បកម្មជាលក្ខណៈគ្រួសារក្នុងតំបន់របស់ខ្លួន ជាពិសេសនៅតាមតំបន់ឆ្ងាយពីប្រភពទឹកធម្មជាតិ ដែលផលត្រីធម្មជាតិមិនអាចបំពេញបានតាមតម្រូវការប្រើប្រាស់របស់ប្រជាកសិករ ។ ដូចនេះ តម្រូវការកូនត្រីពូជសម្រាប់ផ្គត់ផ្គង់ដល់ការអភិវឌ្ឍន៍វារីវប្បកម្មជាបញ្ហាសំខាន់ និងមានសារៈប្រយោជន៍បំផុត ។

បច្ចុប្បន្ន ការអភិវឌ្ឍន៍វារីវប្បកម្មជាលក្ខណៈគ្រួសារ កំពុងត្រូវបានជួយឧបត្ថម្ភគាំទ្រពីសំណាក់រាជរដ្ឋាភិបាលរួមសហការជាមួយបណ្តាអង្គការជាតិ និងអន្តរជាតិ ដូចជា PADEK, AIT-AARM, SCALE, MRC-AIMS, WFP, CRS, JICA ។ល។ សកម្មភាពនេះជាសក្តានុពលភាពមួយយ៉ាងល្អ សម្រាប់ការជួយជំរុញដល់កិច្ចអភិវឌ្ឍន៍ និងការកែលំអឱ្យបានប្រសើរឡើងនូវការផលិតកូនត្រីពូជទាំងបរិមាណ និងគុណភាព ។

## ២.២- ការជ្រើសរើសទីកន្លែង ដើម្បីអភិវឌ្ឍផលិតកម្មកូនត្រីពូជ

### ២.២.១- លក្ខណៈប្រភពទឹក

ការផលិតកូនត្រីពូជ ខុសពីការចិញ្ចឹមត្រីយកសាច់ គឺតម្រូវឱ្យមានប្រភពទឹកគ្រប់គ្រាន់ពេញមួយឆ្នាំសម្រាប់ដំណើរការផលិតកម្មកូនត្រីពូជ ។ ប៉ុន្តែគ្រប់ស្រះទាំងអស់ក៏តម្រូវមិនឱ្យលិចទឹកផងដែរ ដូចជានៅរដូវវស្សាជាដើម ពីព្រោះវាធ្វើឱ្យត្រីស្រែចូលស្រះផលិតកូនត្រី នឹងស៊ីកូនត្រីអស់ ម្យ៉ាងទៀតទឹកជំនន់នឹងធ្វើឱ្យកូនត្រីរួចចេញពីស្រះទៀតផង ។ទោះជានៅកន្លែងខ្លះដែលពុំមានប្រភពទឹកគ្រប់គ្រាន់ កសិករនៅតែអាចដំណើរការផលិតកូនត្រីពូជ ប៉ុន្តែទិន្នផលកូនត្រីពូជ ពុំបានទទួលបរិមាណច្រើន ដូចកន្លែងដែលមានប្រភពទឹកគ្រប់គ្រាន់ ។ ជាទូទៅកសិដ្ឋានបង្កាត់ ភ្ញាស់កូនត្រីពូជ ពឹងផ្អែកលើប្រភពទឹកស្រះដែលបានមកពីទឹកភ្លៀង ។ ដូចនេះ នៅក្នុងកសិដ្ឋានផលិតកូនត្រីពូជ ស្រះខ្លះតម្រូវឱ្យមានទំហំធំ និងជ្រៅ ដើម្បីរក្សាទឹកឱ្យមានពេញមួយឆ្នាំសម្រាប់ដំណើរការសកម្មភាពបង្កាត់ ភ្ញាស់ និងបំប៉ន។ ក្រៅពីនេះកសិដ្ឋានផលិតកម្ម កូនត្រីពូជគួរឱ្យមានអណ្តូងទឹក សម្រាប់ផ្គត់ផ្គង់ទឹកនៅពេលខ្វះទឹក ជាពិសេសនៅរដូវប្រាំង ។ ពេលខ្លះកសិករផលិតកូនត្រីអាចចំណាយថវិកាសម្រាប់បូមទឹក ដើម្បីដំណើរការផលិតកម្មកូនត្រីពូជ ពីព្រោះការផលិតកូនត្រីពូជផ្តល់ផលចំណេញច្រើន។

### ២.២.២- លក្ខណៈតំបន់អភិវឌ្ឍន៍ផលិតកម្មកូនត្រីពូជ

ការអភិវឌ្ឍន៍កសិដ្ឋានផលិតកូនត្រីពូជ គួរជ្រើសរើសនៅតំបន់ឆ្ងាយពីប្រភពទឹកធម្មជាតិ ដែលផលត្រីធម្មជាតិមិនអាចផ្គត់ផ្គង់ការប្រើប្រាស់របស់កសិករបាន ។ ក្នុងករណីនេះបានជំរុញកសិករនៅតាមជនបទចូលរួមការងារចិញ្ចឹមត្រីហើយកូនត្រីពូជដែលផលិតបាននឹងផ្គត់ផ្គង់តាមតម្រូវការដល់កសិករយកទៅចិញ្ចឹមនៅតំបន់ខ្សត់ត្រីធម្មជាតិទាំងនោះ ។បទដ្ឋានអនុវត្តបច្ចេកវិទ្យាស្តីពីការផលិតកូនត្រីពូជទីឡាព្យ៉ានេះ ផ្សព្វផ្សាយដល់កសិករយកទៅអនុវត្ត (ទាំងកំពុងអនុវត្ត និងបំរុងយកទៅអនុវត្ត) ផលិតកម្មកូនត្រីពូជនៅតំបន់ឆ្ងាយពីប្រភពទឹកធម្មជាតិ ដើម្បីជៀសវាងត្រីទីឡាព្យ៉ាដែលជាប្រភេទត្រី ក្រៅស្រុកនេះរួចចូលក្នុងតំបន់ទឹកធម្មជាតិ ។

### ២.២.៣- លក្ខណៈសេដ្ឋកិច្ចសង្គម

គោលនយោបាយនៃរាជរដ្ឋាភិបាលបានគាំទ្រយ៉ាងខ្លាំងដល់ការងារអភិវឌ្ឍន៍វារីវប្បកម្ម ជាពិសេសនៅតំបន់ជនបទ ដើម្បីជួយកែលំអការចិញ្ចឹមជីវិតរបស់កសិករក្រីក្រ ។ ការផលិតកូនត្រីពូជ ជាផ្នែកមួយយ៉ាងសំខាន់នៃការអភិវឌ្ឍន៍សកម្មភាពវារីវប្បកម្ម ហើយក៏ជាការផ្សព្វផ្សាយមួយយ៉ាងខ្លាំងរបស់រាជរដ្ឋាភិបាលក្នុងការងារអភិវឌ្ឍន៍វារីវប្បកម្មនៅតាមជនបទ ដើម្បីផ្តល់ឱកាសឱ្យកសិកររកប្រាក់ចំណូលបានច្រើនពីការផលិតកូនត្រីពូជនេះ ក្រៅពីការងារធ្វើស្រែ ចំការ ។

## ២.៣- ការជ្រើសរើសកសិករ សម្រាប់ផ្សព្វផ្សាយបច្ចេកទេសផលិតកូនត្រីពូជ

គោលការណ៍ខាងក្រោមនេះ ជាលក្ខណៈវិនិច្ឆ័យសំខាន់ៗនៃការជ្រើសរើសកសិករ ដើម្បីដំណើរការផលិតកម្មកូនត្រីពូជ ដោយផ្អែកលើបទពិសោធន៍ និងការសិក្សា វិភាគច្បាស់លាស់ទៅលើការអភិវឌ្ឍន៍ផលិតកម្មកូនត្រីពូជជាលក្ខណៈគ្រួសារ ។

**បុគ្គលិកលក្ខណៈរបស់កសិករ**

- ជាកសិករឧស្សាហ៍ព្យាយាម មានបទពិសោធន៍ច្រើនលើបច្ចេកទេសចិញ្ចឹមត្រី និងទីផ្សារ
- ពេញចិត្តនឹងមុខរបរផលិតកម្មកូនត្រីពូជ និងព្យាយាមធ្វើការងារ
- ចូលរួមសហការការងារជាមួយបុគ្គលិកផ្សព្វផ្សាយរបស់គម្រោង
- មានទំនាក់ទំនងល្អជាមួយប្រជាជនក្នុងភូមិ និងក្រៅភូមិ ។

**ធនធានរបស់កសិករ**

- បើមានលទ្ធភាព គួរមានផ្ទៃដីកន្លះហិកតា សម្រាប់ពង្រីកស្រះបំប៉នត្រីឱ្យបានច្រើន
- ស្រះត្រីគួរមានប្រាំ ដូចជា ស្រះធំមួយសម្រាប់ចិញ្ចឹមត្រីយកសាច់ ស្រះត្រីមេពូជទីឡាព្យ៉ាចំនួន ២ ស្រះបង្កាត់ ឬស្រះផលិតកូនត្រីពូជចំនួន ១ និងស្រះបំប៉ន ១។ ប្រសិនបើស្រះត្រីមានចំនួនច្រើនជាង ៥ នោះកសិករនឹងផលិតកូនត្រីពូជបានកាន់តែច្រើន ។ ម្យ៉ាងទៀតស្រះទាំងអស់ត្រូវរក្សាទឹកឱ្យបានយូរ ដើម្បីផលិតកូនត្រីពូជឱ្យបានច្រើន ។
- មានត្រីមេពូជទីឡាព្យ៉ា
- មានប្រភពទឹក ដែលអាចផ្គត់ផ្គង់ទឹកក្នុងស្រះត្រីបានពេញមួយឆ្នាំ
- យ៉ាងហោចណាស់ ក៏មានស្រះត្រីធំមួយសម្រាប់ផ្គត់ផ្គង់ទឹកពេញមួយឆ្នាំ ឬមានអណ្តូងទឹកមួយ
- មានម៉ាស៊ីនបូមទឹក ១ សម្រាប់បូមទឹកចេញ ចូលស្រះត្រី
- មានអួនសម្រាប់អូសចាប់ត្រីមេពូជ និងកូនត្រី
- មានកម្លាំងពលកម្ម សម្រាប់ដំណើរការផលិតកម្មកូនត្រី
- មានធនធានចំណីធម្មជាតិក្នុងភូមិ សម្រាប់ត្រី ដូចជា ចក កណ្តៀរ ជន្លេន ជាដើម .....
- មានធនធានជីធម្មជាតិក្នុងភូមិ សម្រាប់ត្រី ដូចជា ជីលាមកសត្វ គោ ក្របី ជ្រូក មាន់ ជាដើម
- មានទុនសម្រាប់ដំណើរការផលិតកូនត្រីពូជ ។

**ធនធានក្នុងភូមិ**

- មានស្រះច្រើនក្នុងភូមិ ឃុំ សម្រាប់ចិញ្ចឹមត្រី
- មានប្រជាកសិករជាច្រើនក្នុងភូមិ និងក្រៅភូមិចាប់អារម្មណ៍ និងចូលរួមការងារចិញ្ចឹមត្រី

❑ ខ្វះខាតសាច់ត្រីទទួលទានដូចជា ត្រីស្រែ ក្លាម ខ្សង ខ្ទោ ជាដើម ពុំមានសម្បូរនៅរដូវភ្លៀង ឬរដូវប្រាំង។

## ២.៤- លក្ខណៈជីវសាស្ត្រត្រីទីឡាព្យ៉ា

ត្រីទីឡាព្យ៉ាមានប្រភពមកពីទ្វីបអាហ្វ្រិក ប៉ុន្តែត្រូវបានបណ្តាប្រទេសជាច្រើនលើពិភពលោកបាននាំយកមកចិញ្ចឹម និងផលិតពូជ ហើយគេអាចឃើញមាននៅគ្រប់ទីកន្លែង។ ត្រីទីឡាព្យ៉ា (អំបូរ Cichlidae ) មានយ៉ាងហោចណាស់ ១៤ប្រភេទ ដែលជាប្រភេទត្រីចិញ្ចឹមក្នុងស្រះបានល្អ។ លក្ខណៈពណ៌សម្បុរលើដងខ្លួនត្រីមានភាពខុសគ្នាបន្តិចបន្តួច អាស្រ័យលើប្រភេទត្រីនីមួយៗ ។ កាលពីមុន ត្រីទីឡាព្យ៉ាប្រភេទ ម៉ូសំប៊ិច (*Oreochromis mossambicus*) ជាប្រភេទត្រីពេញនិយមចិញ្ចឹមក្នុងស្រះ។ ក្រោយមកមានប្រភេទត្រីទីឡាព្យ៉ានីលឡូទីកូស (*Oreochromis niloticus*), ដែលពណ៌សម្បុរនៅលើដងខ្លួនត្រីមានលក្ខណៈស្រាលជាងពណ៌សម្បុរលើដងខ្លួនត្រីទីឡាព្យ៉ាម៉ូសំប៊ិច (*Oreochromis mossambicus*)។ ក្រៅពីនេះ នៅមានត្រីទីឡាព្យ៉ាក្រហម (*Oreochromis spp. hybrids*) ក៏ជាប្រភេទត្រីចិញ្ចឹមក្នុងស្រះបានល្អដូចគ្នា ។ ប្រភេទត្រី ទីឡាព្យ៉ាក្រហមនេះ ជាប្រភេទត្រីកូនកាត់ ដែលផលិតចេញពីប្រភេទ *Oreochromis mossambicus* និង *Oreochromis niloticus* (Taiwanese red tilapia) ឬ ផលិតចេញពីប្រភេទ *Oreochromis mossambicus-hornorum* និង *Oreochromis niloticus* (Philippine red tilapia) ។



ត្រីទីឡាព្យ៉ា នីលឡូទីកូស (*Oreochromis niloticus*)



ត្រីទីឡាព្យ៉ាក្រហម (*Oreochromis spp. hybrids*)

ត្រីទីឡាព្យ៉ា ជាប្រភេទត្រីគ្រប់គ្រង ថែរក្សាពង និងកូនត្រីរបស់ខ្លួនដែលទើបនឹងញាស់បានល្អនៅក្នុងស្រះ។ នេះជាលទ្ធភាពមួយដ៏ល្អសម្រាប់ឱ្យកសិករអាចបង្កាត់ និងថែបំប៉នកូនត្រីមេទ្បទីឡាព្យ៉ាបានច្រើន ពីព្រោះត្រីប្រភេទផ្សេងទៀតមិនអាចធ្វើបានដូចប្រភេទត្រីទីឡាព្យ៉ាទេ ដូចនេះវាងាយនឹងងាប់ក្រោយពេលញាស់ជាកូនត្រីហើយ។ ម្យ៉ាងទៀតត្រីទីឡាព្យ៉ាឆាប់ទទួលភាពពេញវ័យបន្តពូជ នៅពេលវាមានទំហំតូចនៅឡើយ ហើយចាប់ផ្តើមផលិតពូជរហូតដោយមិនបានរីកឡើងទម្ងន់បន្តទៀត ។ ប្រសិនបើកសិករមិនចង់ឱ្យត្រីឆាប់ទទួលភាពពេញវ័យរហ័ស កសិករគួរតែថែបំប៉នត្រីមេពូជទីឡាព្យ៉ាញី ឈ្មោលដាច់ដោយឡែកពីគ្នា មុនពេលវាមានអាយុពេញវ័យគ្រប់គ្រាន់ ដើម្បីផលិតពូជ។

| លក្ខណៈទូទៅ | លក្ខណៈពេញវ័យបន្តពូជ |
|---|---|
| - ជាប្រភេទត្រីក្រៅស្រុក ស៊ីចំណីចំរុះ<br>- សាច់ត្រីមានរសជាតិឆ្ងាញ់ ប្រជាជនចូលចិត្តចិញ្ចឹម<br>- រយៈពេលចិញ្ចឹម ពី ៦-៨ខែ | - ងាយស្រួលពង កូនក្នុងស្រះធម្មជាតិ<br>- ទំងន់ត្រីមេ ពូជ ៥០-១០០ក្រាម<br>- ទំងន់ត្រីមេ ពូជ ដែលល្អ ពី ១០០-១៥០ក្រាម |
| - ជាប្រភេទត្រីងាយស្រួលចិញ្ចឹម ឆាប់លូតលាស់<br>- វាមានទំងន់ពី ១០០-៣០០ក្រាម | - អាយុត្រីមេពូជ ពី ៤-៦ខែ<br>- ប្រវែងត្រីមេពូជ ពី ១០-១២ស.ម |

| | |
|---|---|
| - សីតុណ្ហភាពសមស្រប សម្រាប់ចិញ្ចឹម ពី ២៥- ៣០អង្សារសេ<br>- សីតុណ្ហភាពទាបដែលត្រីអាចរស់នៅបាន ១១អង្សារសេ | - អាចបន្តពូជពី ៦-១០ដង ក្នុង ១ឆ្នាំ<br>- បរិមាណគ្រាប់ពងអាចពងក្នុង ១ឆ្នាំ ៦.០០០<br>- បរិមាណគ្រាប់ពងអាចពងក្នុង ១ដង ៦០០-១.០០០ |
| - អាចចិញ្ចឹមបានល្អក្នុងទឹកដែលមានកំហាប់អំបិល ២០ភាគពាន់<br>-ធន់នឹងជំងឺ និងគុណភាពទឹកក្រខ្វក់ ដែលមានកំរិតអុកស៊ីសែនរលាយទាប ពី ២-៣ មីលីក្រាម ក្នុង ១លីត្រទឹក និង pH=៤-៥ | សីតុណ្ហភាព ពង-កូនៈ<br>- កំរិតសមស្រប ២៥-៣០អង្សារសេ<br>- កំរិតទាប ២១អង្សារសេ |
| - កូនត្រីទីឡាព្យ៉ាស៊ីសត្វល្អិតប្លង់តុង ដែលមាននៅក្នុងស្រះ<br>- ត្រីទីឡាព្យ៉ាធំ ស៊ីសត្វល្អិតប្លង់តុង ប្រភេទសត្វល្អិតក្នុងទឹក-នៅស្រទាប់បាត ចក កាកសំណល់បន្លែ ចំណីគ្រាប់ពីរោងចក្រ | កំរិតទំលាក់ពង ១ដង ក្នុងត្រីមេ ១ក្បាលៈ<br>- មានពី ១០០-២.០០០គ្រាប់ពង<br>- ជាមធ្យមមាន ២០០-៤០០គ្រាប់ពង<br>ត្រីមេ ១ក្បាលទំងន់ ២០០ក្រាមផលិតកូនត្រីម្សៅ (កូនត្រីតូចៗ) បានចំនួន ២៥០-៥០០ក្បាល ក្នុងរយៈពេលពី ៤-៥សប្តាហ៍ |
|   | - ត្រីមេទីឡាព្យ៉ា ភ្ញាស់ពងត្រី នៅក្នុងមាត់របស់វា<br>- ពងត្រីនឹងញាស់ក្នុងរយៈពេលពី ៣-៥ថ្ងៃ ហើយក្រោយពេលពងត្រីញាស់ ត្រីមេនៅបណ្តើរកូនពី ៨-១០ថ្ងៃ ទើបវាឈប់បណ្តើរកូន ។ |

## ២.៥- របៀបជីកស្រះ សម្រាប់ផលិតកម្មកូនត្រីពូជទីឡាព្យ៉ា

ការជីកស្រះផលិតកូនត្រីពូជ ខុសពីការជីកស្រះចិញ្ចឹមត្រីសាច់ ដូចជាការជីកស្រះបង្កាត់ និងស្រះបំប៉ន ព្រមទាំងគុណភាពដីស្រះនោះ មានឥទ្ធិពលទៅលើផលិតកម្មកូនត្រីពូជ ។

### ២.៥.១- ការជ្រើសរើសទីតាំងជីកស្រះ

ការជ្រើសរើសទីតាំងជីកស្រះ សម្រាប់ដំណើរការផលិតកម្មកូនត្រីពូជ ជាបញ្ហាសំខាន់ និងចំបង ពីព្រោះវាទាក់ទងនឹងការចំណាយ និងការដំណើរការគ្រប់គ្រង ។ ទីតាំងសមស្របសម្រាប់ដំណើរការផលិតកូនត្រី គឺជាទីកន្លែងដែលកសិករងាយស្រួលក្នុងការគ្រប់គ្រង និងការត្រួតពិនិត្យមើលស្រះបានរាល់ថ្ងៃ ។ សកម្មភាពទាំងនោះមានដូចជាការដាក់ចំណីការបាចជី ការត្រួតពិនិត្យមើលគុណភាពទឹកស្រះ ការពិនិត្យមើលជំងឺត្រី និងការឃ្លាំមើលអ្នកលួចត្រីជាដើម ។ល ។ ចំពោះកសិករនៅតាមជនបទ ស្រះត្រីគួរតែជីកនៅក្បែរផ្ទះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ។ ទីតាំងសមស្របដែលជ្រើសរើសសម្រាប់ជីកស្រះ ត្រូវអនុវត្តតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ៖

- គ្មានដើមឈើដុះគ្របម្លប់ពីលើស្រះត្រី (សូមមើលរូបភាពខាងក្រោម)
- គុណភាពដីអាចរក្សាទឹកក្នុងស្រះ បានពេញមួយឆ្នាំ
- ជាទីតាំងត្រូវការពារកុំឱ្យលិចទឹកនៅរដូវវស្សា
- គួរស្ថិតនៅឆ្ងាយពីវាលស្រែ ជាពិសេសស្រះបំប៉នកូនត្រី ដើម្បីកុំឱ្យត្រីស្រែលោតចូល
- ជាទីតាំងនៅឆ្ងាយពីតំបន់ដែលមានប្រើប្រាស់ថ្នាំពុល (សូមមើលរូបភាពខាងក្រោម)
- ស្ថិតនៅជិតផ្ទះ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ។

ទឹកក្នុងស្រះត្រីទាមទារឱ្យមានពន្លឺព្រះអាទិត្យចាំងចូលដើម្បីឱ្យចំណើធម្មជាតិ (រុក្ខជាតិ និងសត្វប្លង់តុង និង សត្វល្អិតដទៃទៀត) ដែលជាចំណើសំខាន់សម្រាប់ត្រីលូតលាស់បានល្អក្នុងទឹកស្រះ ។ ស្លឹកប្រភេទរុក្ខជាតិមួយចំនួនមានជាតិពុលគួរកុំឱ្យមាននៅក្នុងស្រះត្រី ដើម្បីកុំឱ្យត្រីងាប់ ។




ស្រះត្រីសមស្របគ្មានដើមឈើដុះគ្របម្លប់ពីលើស្រះ



ស្រះត្រីមិនសមស្របបើស្ថិតនៅក្នុងតំបន់មានការប្រើប្រាស់ថ្នាំពុល

## ២.៥.២- គុណភាពដី សម្រាប់ស្រះចិញ្ចឹមត្រី

ដីដែលមានដីឥដ្ឋភាគច្រើនជាប្រភេទដីល្អ និងតម្រូវការចាំបាច់ក្នុងការជីកស្រះចិញ្ចឹមត្រីដើម្បីរក្សាទឹកក្នុងស្រះត្រីឱ្យបានយ៉ាងហោចណាស់ពី ៦-៨ខែ ។ ដីឥដ្ឋដែលមានសារជាតិល្បប់ (ដីជីវជាតិល្អ pHមាននៅក្នុងចន្លោះ ៦.៥-៨ ) ជាប្រភេទដីសមស្របសម្រាប់ការចិញ្ចឹមត្រី ពីព្រោះវាអាចរក្សាទឹកក្នុងស្រះបានយូរ និងថែមទាំងផ្តល់ជីដល់ស្រះត្រីទៀតផង ។

### ការពិនិត្យមើលគុណភាពដី

ជីករណ្តៅមួយដែលមានអង្កត់ផ្ចិត ០,៦ម៉ែត្រ និងជម្រៅ ០,៨ម៉ែត្រ រួចចាក់ទឹកបំពេញ ហើយរង់ចាំរយៈពេល ២-៣ថ្ងៃ ។ ប្រសិនបើមានឃើញនៅសល់ទឹកខ្លះ នោះបញ្ជាក់ថាដីប្រភេទនោះអាចជីកស្រះចិញ្ចឹមត្រីបាន ។



សកម្មភាពជីករណ្តៅ



ចាក់ទឹកបំពេញ



២ថ្ងៃក្រោយនៅមានទឹកក្នុងរណ្តៅ



អាចជីកស្រះចិញ្ចឹមត្រីបាន

## ២.៥.៣- របៀបជីកស្រះចិញ្ចឹមត្រី

ការជីកស្រះត្រីសម្រាប់ផលិតកូនត្រីទីឡាព្យ៉ា គឺមានការខុសគ្នានឹងការជីកស្រះចិញ្ចឹមត្រីយកសាច់ ។ ការជីកស្រះផលិតកូនត្រីពូជទីឡាព្យ៉ា ត្រូវអនុវត្តតាមរបៀបជីកដូចខាងក្រោម ៖

- ស្រះត្រីមេពូជគួរជីកឱ្យមានទំហំពី ២០០-៣០០ម៉ែត្រការ៉េ

- ស្រះបំប៉នកូនត្រីត្រូវជីកឱ្យមានទំហំពី ៨០-១៥០ម៉ែត្រការ៉េ ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង
- ស្រះត្រីទាំងអស់ត្រូវជីកឱ្យមានរាងជាចតុកោណកែង ដើម្បីងាយស្រួលក្នុងការប្រមូលផល
- ស្រះត្រីត្រូវជីកឱ្យមានជម្រៅរាក់ល្មមពី ០,៨-១ម៉ែត្រ
- បាតស្រះត្រូវជីកឱ្យមានជំរាលទៅជ្រុងម្ខាងនៃស្រះ  ព្រោះក្រោយពេលបូមទឹកចេញពីស្រះ ទឹកនឹងដក់នៅជ្រុងម្ខាងនៃស្រះ ពេលនោះកសិករនឹងស្រួលក្នុងការប្រមូលផល ។
- គ្រប់ជ្រុងទាំង ៤ នៃស្រះត្រី  ត្រូវជីកឱ្យមានជំរាល ១ៈ ២ (សូមមើលរូបភាពខាងក្រោម) ដើម្បីមានប្រយោជន៍មិនត្រឹមតែការបង្កើតឱ្យមានលក្ខខណ្ឌល្អសម្រាប់ស្រះចិញ្ចឹមត្រី ឱ្យមានសម្បូរខ្យល់អុកស៊ីសែន និងចំណី ធម្មជាតិនៅក្នុងស្រះត្រីប៉ុណ្ណោះទេ  ប៉ុន្តែភាពជំរាលនៃជ្រុងស្រះនេះជាទីកន្លែងបង្កាត់ពងត្រីទីឡាព្យ៉ា ។








ស្រះត្រីជីកបានល្អតាមបច្ចេកទេស


ងាយធ្វើឱ្យទឹកស្រះប្រែពណ៌បៃតង

អាចម៍ដីដែលជីកបានត្រូវយកមកធ្វើជាភ្លឺស្រះ ។ ជាទូទៅដីនៅស្រទាប់លើជាប្រភេទដីមានជីវជាតិល្អ ហើយត្រូវយកមកក្រាលលើភ្លឺស្រះ ដើម្បីទុកដាំស្មៅ កុំឱ្យទឹកភ្លៀងហូរច្រោះបាក់ភ្លឺស្រះ ។ ក្នុងពេលជីកស្រះត្រីបើកសិករមានលទ្ធភាពគួរដាក់បំពង់បង្ហូរក្នុងភ្លឺស្រះ ដើម្បីទុកសម្រាប់បង្ហូរទឹក ចេញ ចូលស្រះត្រី  ម្យ៉ាងទៀតកសិករអាចជីកជាចង្អូរ តភ្ជាប់ពីស្រះត្រីទៅវាលស្រែ (ក្នុងករណីមានស្រែជាប់នឹងស្រះត្រីដែលកំពុងជីក)  ដើម្បីឱ្យត្រីទៅស៊ីចំណីក្នុងវាលស្រែ (សម្រាប់ការថែបំប៉នកូនត្រីមានទំហំធំ) ។

## ២.៦- ការរៀបចំស្រះ មុនពេលដាក់ត្រីមេពូជ

ការរៀបចំស្រះជាចំណុចចាប់ផ្តើមសំខាន់ ក្នុងដំណើរការផលិតកូនត្រីពូជ។ ក្រោយពេលជីកស្រះត្រីរួចហើយ ទាមទាររៀបចំស្រះឱ្យបានល្អត្រឹមត្រូវតាមបច្ចេកទេសដូចខាងក្រោម មុនពេលដាក់ត្រីមេពូជបង្កាត់ ឬ ដាក់កូនត្រីបំប៉ន ៖

- ❑ ស្រះផលិតកូនត្រីពូជ ត្រូវជៀសវាងកុំឱ្យមានត្រីស្រែ
- ❑ ទឹកស្រះត្រូវឱ្យមានសម្បូរចំណីធម្មជាតិ (ប្លង់តុង) ដែលជាចំណីសំខាន់សម្រាប់ត្រី
- ❑ ទឹកស្រះត្រីត្រូវមានកំរិត pH (ជាតិជូរ)ពី ៦,៥-៨
- ❑ ទឹកស្រះត្រូវធ្វើឱ្យមានសម្បូរខ្យល់អុកស៊ីសែន

ក្នុងករណីខ្លះ បើកសិដ្ឋានផលិតកូនត្រីពូជនៅជាប់នឹងវាលស្រែដែលសម្បូរត្រីស្រែ ស្រះត្រីក្នុងកសិដ្ឋាននោះ ត្រូវបាំងព័ទ្ធជុំវិញដោយរនាំងសំណាញ់ប្លាស្ទិក (សូមមើលរូបភាពខាងក្រោម) ឬក៏លើកភ្លឺស្រះឱ្យខ្ពស់ ដើម្បីជៀសវាងត្រីស្រែលោតចូលក្នុងស្រះបង្កាត់ និងស្រះបំប៉នកូនត្រីពូជ ។





ការព័ទ្ធសំណាញ់ជុំវិញស្រះផលិតកូនត្រីទីឡាព្យ៉ាមុនពេល និងក្រោយពេលដាក់ត្រីមេពូជបង្កាត់ ឬ ថែបំប៉ន

### ២.៦.១- ការស្តារភក់បាតស្រះ

នៅស្រទាប់ខាងលើភក់បាតស្រះ ជាមជ្ឈដ្ឋានរស់នៅដ៏ល្អរបស់ពពួកវារីសត្វ ដូចជា ខ្យង ខ្ចៅ និង ជន្លេន ជាដើមដែលជាចំណីអាហារសំខាន់សម្រាប់ត្រី ។ តែទោះជាយ៉ាងណាក៏ដោយភក់បាតស្រះមិនឱ្យមានជម្រៅលើសពី ២០ សង់ទីម៉ែត្រ ព្រោះវាធ្វើឱ្យបរិមាណខ្យល់អុកស៊ីសែនក្នុងទឹកស្រះថយចុះ និងកើនឡើងឧស្ម័នពុលដូចជា ឧស្ម័នមេតាន និង អាម៉ូនីញាក់ ($CH_4$, $NH_3$)។ រៀងរាល់ឆ្នាំ ក្រោយពីប្រមូលផលត្រីរួច ស្រះចិញ្ចឹមត្រីត្រូវបូមសំអាត និងបារភក់បាតស្រះចេញដោយទុកមិនឱ្យលើសពី ២០សង់ទីម៉ែត្រ ។

### ២.៦.២- ការប្រើប្រាស់កំបោរ និងជី

ការប្រើប្រាស់កំបោរក្នុងការរៀបចំស្រះមានសារៈសំខាន់ណាស់ ព្រោះវាបានកែលំអគុណភាពទឹកពីអាស៊ីត មកបាសបំបាត់ភាពល្អក់នៃទឹកសម្លាប់ត្រីកាច សត្វល្អិតបំផ្លាញកូនត្រី សម្លាប់មេរោគ និងជួយដល់ការប្រើប្រាស់ជី កែលំអគុណភាពទឹកឱ្យមានប្រសិទ្ធិភាព។ កំបោរដែលយកមកប្រើប្រាស់នេះ ជាប្រភេទម្សៅកំបោរសលាបជញ្ជាំងផ្ទះ ការប្រើប្រាស់កំបោរសសម្រាប់រៀបចំស្រះ ត្រូវអនុវត្តដូចខាងក្រោម៖

- ❑ សម្រាប់បាចនៅលើផ្ទៃបាតស្រះ ក្រោយពេលស្តារភក់បាតស្រះ ជារៀងរាល់ឆ្នាំ ក្នុងកំឡុងពេលរៀបចំស្រះ

- ចំពោះស្រះថ្មី គួរប្រើកំបោរសពី ៣-៥គ.ក្រ ក្នុង ១០០ម២ ។ ស្រះចាស់ ពី ៨-១០គ.ក្រ ក្នុង ១០០ម២ ។ ជាទូទៅបរិមាណកំបោរគួរប្រើទៅតាមកំរិតជាតិជូរ (pH) នៃដី ដូចតារាងបញ្ជាក់ខាងក្រោម ។
- កំបោរសត្រូវលាយជាមួយទឹកក្នុងធុងដែក រួចយកឈើកូរឱ្យរលាយ ទើបយកទៅបាចសព្វពេញផ្ទៃស្រះ។ ត្រូវជៀសវាងការយកកំបោរសទៅលាយជាមួយទឹកក្នុងធុងជ័រ ដែលបណ្តាលឱ្យក្តៅ និងរលាយធុងជ័រនោះ ហើយគួរជៀសវាងការដកដង្ហើមស្រូបយកផ្សែង ឬ ម្សៅកំបោរស ។
- ក្រោយពីបាចកំបោរហើយ គួរទុកស្រះហាលថ្ងៃ រយៈពេលពី ១- ២ថ្ងៃ ។

| កំរិត pH | ប្រភេទដី | បរិមាណកំបោរត្រូវប្រើ(គ.ក្រ ក្នុង ១០០ម២) |
|---|---|---|
| ៤-៥ | អាស៊ីតខ្ពស់ | ២០ |
| ៥-៦,៥ | អាស៊ីតមធ្យម | ១០ |
| ៦,៥-៧,៥ | ធម្មតា | ៥ |
| ៧,៥-៨,៥ | ជាតិបាស | ២ |
| ៨,៥-៩,៥ | ជាតិបាស ខ្លាំង | 0 |




ការបាចកំបោរសលើផ្ទៃបាតស្រះ ចាស់ និង ថ្មី

- រួចបង្ហូរទឹកចូលក្នុងស្រះប្រមាណ ១ ភាគ ៣ នៃបរិមាណទឹកសរុប ដោយឆ្លងកាត់តម្រង រួចទុកស្រះរយៈពេល ២-៣ថ្ងៃ។
- ដាក់លាមកសត្វ ឬ អាចដាក់បន្ថែមរុក្ខជាតិបៃតងទៅក្នុងស្រះតូចមួយរួចទុករយៈពេលពី ៣-៥ថ្ងៃ ទើបទឹកក្នុងស្រះក្លាយជាទឹកជី ពេលនោះយើងអាចដួសទឹកនោះមកដាក់ចូលក្នុងស្រះចិញ្ចឹមត្រីបាន។ នេះជាវិធីមួយដ៏ល្អដែលយើងគួរយកមកអនុវត្ត ព្រោះវិធីនេះកាត់បន្ថយបានទូវការប្រើប្រាស់បរិមាណអុកស៊ីសែនពីក្នុងស្រះ។
- បន្ទាប់មកកសិករអាចបង្ហូរទឹកចូលក្នុងស្រះឱ្យពេញល្មមតាមតម្រង និងត្រូវយកបន្ទះក្តារដាក់ទ្រពីក្រោម កម្លាំងទឹកហូរដើម្បីជៀសវាងការធ្វើឱ្យទឹកស្រះល្អក់ ។
- ក្នុងករណីទឹកស្រះមិនទាន់មានពណ៌បៃតងល្អ កសិករអាចលែលកដាក់ជីបន្ថែមបន្តិចទៀត រហូតដល់ទឹកស្រះមានពណ៌បៃតងល្អ ។

នៅពេលទឹកស្រះមានពណ៌បៃតងល្អ នោះបញ្ជាក់ថាទឹកស្រះនោះមានសម្បូរពពួកសត្វល្អិត ដែលហៅថា សត្វបួងតុង

និងមានពពួករុក្ខជាតិថ្នាក់ទាប ដែលហៅថា រុក្ខជាតិប្លង់តុង ហើយវាជាចំណីធម្មជាតិយ៉ាងសំខាន់សម្រាប់ការរស់នៅរបស់ត្រី។ យើងអាចត្រួតពិនិត្យវត្តមាន សត្វប្លង់តុងបាន តាមរយៈការដួសទឹកពីជ្រុងម្ខាងនៃស្រះដោយប្រើក្រមា រួចយកកែវដួសទឹកចេញពីក្រមា ពេលនោះយើងនឹងសង្កេតឃើញសត្វល្អិតតូចៗនៅក្នុងកែវ (សូមមើលរូបភាពខាងក្រោម)។



របៀបត្រួតពិនិត្យប្លង់តុងក្នុងស្រះចិញ្ចឹមត្រី



រូបភាពសត្វល្អិតប្លង់តុងក្នុងកែវ

ក្នុងករណីទឹកស្រះមិនទាន់មានពណ៌បៃតងល្អ កសិករអាចប្រើជីគីមីបន្ថែមដូចជា ជីអ៊ុយរ៉េ និងជីដេអាប៉េ (ដូចមានរូបភាពបង្ហាញ) ក្នុងកំរិតជីអ៊ុយរ៉េ ៣០០ក្រាម និងជីដេអាប៉េ ១០០ក្រាម ក្នុងផ្ទៃទឹកស្រះ ១០០ម²។ ប៉ុន្តែយើងក៏អាចប្រើជីធម្មជាតិដូចបានរៀបរាប់ខាងលើ ។ នៅពេលទឹកស្រះមានពណ៌បៃតងហើយ យើងត្រូវបញ្ឈប់ការប្រើប្រាស់ជីភ្លាម ។




ប្រភេទជីគីមី ដេអាប៉េ និងជី អ៊ុយរ៉េ




ការប្រើប្រាស់ជីគីមីនៅក្នុងស្រះចិញ្ចឹមត្រី ១០០ម²

## ២.៦.៣- ការត្រួតពិនិត្យគុណភាពទឹក

<u>ការវាស់វែងកំរិតថ្លានៃទឹកស្រះ</u>- យើងអាចប្រើថាសដែក ឬ ឈើដែលមានលាបពណ៌ស និងខ្មៅឆ្លាស់គ្នាដូចរូបភាពខាងក្រោមបានបញ្ជាក់ ដើម្បីធ្វើការវាស់ស្ទង់មើលកំរិតថ្លានៃទឹក ។ ថាសដែក ឬ ឈើនោះ ជាទូទៅមានរាងមូល មានអង្កត់ផ្ចិតពី ២០ ទៅ ២៥ស.ម ហើយត្រូវតភ្ជាប់ដោយដងឈើ ឬ ខ្សែ ដែលមានគំនូសក្រិតជាសង់ទីម៉ែត្រ ដើម្បីវាស់វែងកំពស់ទឹក។ យើងអាចធ្វើការវាស់ស្ទង់មើលកំរិតថ្លានៃទឹក ដោយដាក់ថាសដែក ឬ ឈើនោះ ជម្រុជទៅក្នុងទឹកបន្តិចម្តងៗ រហូតដល់ជម្រៅទឹកដែលយើងនៅមើលឃើញពណ៌ស-ខ្មៅនៃថាសនោះ ។ បើសិនជាថាសដែកនោះនៅមើលឃើញក្នុងជម្រៅទឹក ៣០ស.ម នោះបញ្ជាក់ថា ទឹកស្រះនោះមិនមានភាពល្អក់។ ផ្ទុយទៅវិញក្នុងករណីថាសដែកមិនអាចមើលឃើញភ្លាមៗ ពេលដាក់ចូលក្នុងទឹកនោះបញ្ជាក់ថាទឹកស្រះនោះល្អក់ ឬមានជីច្រើនពេក (ដែលភាគច្រើនមានពណ៌បៃតង ខ្លាំង) ។







ថាស **Secchi Disc** សម្រាប់វាស់គុណភាពទឹក និងក្រដាស **pH** សម្រាប់វាស់កំរិតជាតិអាស៊ីតក្នុងទឹកស្រះ

<u>ការវាស់វែងជាតិជូរ ឬ ជាតិអាស៊ីតនៃទឹកស្រះ</u>- យើងអាចធ្វើការវាស់វែងកំរិតជាតិអាស៊ីត ឬជាតិបាសនៃទឹកស្រះចិញ្ចឹមត្រី ដែលគេហៅថា pH ដោយប្រើក្រដាស pH ជ្រលក់ទៅក្នុងទឹកស្រះនោះ (ដូចរូបភាពខាងលើ) ឬ ម្យ៉ាងទៀតបើមានលទ្ធភាពគេប្រើម៉ាស៊ីនវាស់តែម្តង ។ ក្រោយពេលជ្រលក់ទៅក្នុងទឹករួច យើងយកវាមកផ្ទៀងលើ គំរូក្រដាស pH ដែលមានបញ្ជាក់ជាតួលេខ ។ បើ pH តូចជាង 7 ( pH តូចជាង ៧) នោះបញ្ជាក់ថា ទឹកស្រះនោះមានជាតិ អាស៊ីត បើ $pH \le 5$ ( pH តូចជាងឬស្មើ ៥) ទឹកស្រះមានជាតិអាស៊ីតខ្លាំង ដែលធ្វើឱ្យត្រីពិបាករស់នៅ និងមិនអាចរីកធំ ធាត់បាន ។ ក្នុងករណីនេះ យើងអាចប្រើកំបោរ ដើម្បីកែលំអទឹកស្រះដែលមានជាតិអាស៊ីតមកត្រឹម pH = ៦,៥-៨,៥បាន ។

## ២.៧- ការជ្រើសរើសត្រីមេពូជដាក់បង្កាត់

នៅក្នុងផលិតកម្មកូនត្រីពូជ ត្រីមេពូជជាបញ្ហាសំខាន់ដែលតែងតែត្រូវបានយកចិត្តទុកដាក់ ដើម្បីដំណើរការផលិតកូនត្រីទទួលបានជោគជ័យ និងបំពេញបានតាមតម្រូវការរបស់កសិករចិញ្ចឹមត្រី ។ តាមលក្ខណៈបច្ចេកទេសត្រីមេពូជត្រូវគ្រប់គ្រងថែរក្សាឱ្យបានល្អ ដូចបានបញ្ជាក់ក្នុងចំណុចខាងក្រោម (២.១៥) ហើយត្រូវព្យាយាមជ្រើសរើសយកត្រីមេពូជដែលល្អមកដាក់បំប៉ន មុនពេលរៀបចំដំណើរការបង្កាត់ ។ ជាធម្មតា ត្រីមេពូជត្រូវជ្រើសរើសយកពីប្រភពមេបាររបស់វាដែលបានថែរក្សា និងគ្រប់គ្រងបានល្អត្រឹមត្រូវតាមបច្ចេកទេស ។ ការផលិតកូនត្រីពូជទីឡាព្យ៉ាពីស្រះដីជាលទ្ធភាព និងជាមុខរបរមួយល្អសម្រាប់កសិករ ងាយរកប្រាក់ចំណេញបាន បើសិនកសិករមានត្រីមេពូជទីឡាព្យ៉ាល្អ ។ ខាងក្រោមនេះជាលក្ខណៈវិនិច្ឆ័យក្នុងការជ្រើសរើសត្រីមេពូជ ទីឡាព្យ៉ាគុណភាពល្អ៖

- ប្រភពមេបាល្អ ឬទីកន្លែង (តំបន់) ដែលត្រីមេពូជរស់នៅ (សូមមើលមេរៀនចំណុច ២.១៥)
- យកពីត្រីមេបាល្អ ដែលត្រូវបានគ្រប់គ្រង និងថែបំប៉នបានត្រឹមត្រូវតាមបច្ចេកទេស
- ត្រីមេពូជជំនាន់ថ្មីពេញវ័យលូតលាស់ល្អ
- ដងខ្លួនភ្លឺថ្លា (ទាំងទ្រង់ទ្រាយ ស្រកា និងព្រុយ)
- លើដងខ្លួនគ្មានរបួស ឬ ដាំ ដំបៅ រលាក និងគ្មានជំងឺ
- មានការលូតលាស់ល្អ (ទាំងទំហំ និងអាយុ) ។

មុននឹងធ្វើការដឹកជញ្ជូន និងជ្រើសរើសត្រីមេពូជទីឡាព្យ៉ា សម្រាប់រៀបចំដំណើរការសកម្មភាពបង្កាត់

កសិករផលិតកូនត្រីពូជត្រូវស្គាល់អត្តសញ្ញាណត្រីពូជទីឡាព្យ៉ា ញី ឈ្មោល ឱ្យបានច្បាស់លាស់ ដើម្បីជៀសវាងការយល់ច្រឡំរវាងភេទទាំងពីរនេះ ។ រូបភាពខាងក្រោមនេះ គឺជាការបង្ហាញភាពខុសគ្នានៃលក្ខណៈភេទ ញី ឈ្មោល របស់ត្រីមេពូជទីឡាព្យ៉ា ។ ត្រីមេពូជទីឡាព្យ៉ា ញី មានរន្ធ ២ នៅលើដុំពក មួយសម្រាប់បញ្ចេញទឹកនោម និង មួយទៀតសម្រាប់បញ្ចេញពងត្រី ។ ចំណែកត្រីមេពូជ ឈ្មោល មានរន្ធតែ ១ សម្រាប់បញ្ចេញទឹកនោម និងស្ពែម ។




## ២.៨- ការដឹកជញ្ជូនត្រីមេពូជ

ការដឹកជញ្ជូនត្រីមេពូជឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស ពីកសិដ្ឋានមួយទៅដាក់កន្លែងបំប៉ន ឬ បង្កាត់នៅកសិដ្ឋានមួយទៀតមានសារៈសំខាន់ណាស់ ដើម្បីជៀសវាងត្រីមេពូជងាប់ក្នុងរយៈពេលដឹកជញ្ជូន និងដើម្បីផលិតកូនត្រីពូជឱ្យមានគុណភាពល្អ។ ខាងក្រោមនេះ ជាលក្ខណៈបច្ចេកទេសសំខាន់ៗ នៃការដឹកជញ្ជូនត្រីមេពូជ ៖

- ជាដំបូង ត្រូវយកចិត្តទុកដាក់រើសយកត្រីមេពូជ ដែលមានគុណភាពល្អ ដោយអនុវត្តតាមវិធីសាស្ត្រនៅចំណុចមេរៀន ២.៧
- ក្នុងពេលជ្រើសរើសត្រីមេពូជ ឬចាក់អ័រមូន ត្រូវចាប់ត្រីថ្នមៗ កុំឱ្យត្រីមានរបួស ដែលនាំឱ្យត្រីមេពូជអន់គុណភាព ។
- ត្រីមេពូជដែលបានជ្រើសរើសហើយ ត្រូវរក្សាទុកក្នុងហាប៉ា ឬអាងសីម៉ង់ ហើយកុំផ្តល់ចំណីឱ្យស៊ី ១ថ្ងៃ មុនពេលដឹកជញ្ជូន ។
- ការចាប់ត្រី ត្រូវជៀសវាងធ្វើនៅពេលយប់ ដើម្បីកុំឱ្យត្រីងាប់ ពីព្រោះនៅពេលយប់ទឹកស្រះខ្វះខ្យល់អុកស៊ីសែន
- បើដឹកជញ្ជូនផ្លូវជិតៗ យើងអាចប្រើធុង ឆ្នាំង ឬ សម្ភារៈផ្សេងៗទៀត ដែលអាចដឹកជញ្ជូនបាន តែត្រូវ ឱ្យស្អាតគ្មានជាតិពុល ។

- ក្នុងករណីដឹកជញ្ជូនផ្លូវឆ្ងាយ ត្រូវរៀបចំថង់ប្លាស្ទិក ដែលមានទំហំ ៦០x៨០ស.ម និង ត្រូវមានខ្យល់អុកស៊ីសែនសម្រាប់បញ្ចូលក្នុងថង់ត្រី ។ ក្នុងករណីខ្លះ យើងអាចប្រើអំបិល ឬ មេទីឡែនពណ៌ខៀវ ក្នុងកំរិតតែ ២ក្រាម ក្នុង១លីត្រទឹក ដើម្បីសម្លាប់មេរោគ និងបាក់តេរី ដែលអាចមានក្នុងថង់កូនត្រី ។
- ក្នុង ១ថង់ យើងអាចដាក់ត្រីមេពូជពី ២-៥ក្បាល អាស្រ័យទៅនឹងទំហំត្រីមេពូជ និងចំងាយផ្លូវត្រូវដឹកជញ្ជូន
- ទឹកដែលត្រូវដាក់ក្នុងថង់ ឬ ធុងត្រីដឹកជញ្ជូន ត្រូវយកចេញពីស្រះដែលត្រីមេពូជរស់នៅ
- ការដឹកជញ្ជូនត្រី គួរធ្វើនៅពេលព្រឹក ព្រោះអាកាសធាតុនៅត្រជាក់ល្អ
- ក្នុងករណីដឹកជញ្ជូនតាមកង់ ឬ ម៉ូតូ ត្រូវធ្វើយ៉ាងណាកុំឱ្យត្រីត្រូវកំដៅថ្ងៃខ្លាំង ។



របៀបដឹកជញ្ជូនត្រីក្នុងចម្ងាយផ្លូវជិត១ ដោយប្រើធុង ឆ្នាំង ឬ សម្ភារៈស្អាតល្អផ្សេង១ទៀត



ក្នុងករណីដឹកជញ្ជូនត្រីផ្លូវឆ្ងាយ ត្រូវប្រើថង់ប្លាស្ទិក និងត្រូវបំពេញដោយខ្យល់អុកស៊ីសែន

## ២.៩- ការដាក់ត្រីមេពូជបង្ខាត់ក្នុងស្រះ

ការផលិតកូនត្រីពូជទីឡាព្យ៉ាជាលក្ខណៈគ្រួសារ កសិករដែលមានស្រះត្រីតែមួយក៏អាចផលិតកូនត្រីពូជបានដែរ ប៉ុន្តែត្រូវទាមទារឱ្យមានហាប៉ា ១ ឬ ២ សម្រាប់បំប៉នកូនត្រីទីឡាព្យ៉ា ដែលចាប់ចេញពីស្រះ (សូមមើលរូបខាង ក្រោម)។ ហាប៉ាមានតួនាទីសំខាន់សម្រាប់បំប៉នកូនត្រីទំហំតូច១ រហូតដល់មានទំហំធំ (៣-៥ស.ម)។ នៅតាមជនបទកសិករខ្លះមានស្រះ ២-៣ នេះបានផ្តល់លទ្ធភាពឱ្យកសិករដំណើរការផលិតកូនត្រីបានយ៉ាងងាយស្រួល ។ ក្នុងករណីនេះជាទូទៅកសិករផលិតកូនត្រីពូជ ទីឡាព្យ៉ាបានច្រើនជាង កសិករដែលមានស្រះត្រីតែមួយ ។





ការចាប់កូនត្រីទីឡាព្យ៉ាពីស្រះ ដោយប្រើថ្នង　　　　មកដាក់បំប៉នក្នុងហាប៉ា ក្នុងស្រះចិញ្ចឹមត្រី

## ២.៩.១- ការជ្រើសរើសត្រីមេពូជ

ត្រីមេពូជទីឡាព្យ៉ា ដែលមានទំហំពី ៥០-១០០ក្រាម ក្រោយពេលចិញ្ចឹមបានរយៈពេល ៦ខែ ជាទំហំត្រីមេពូជពេញវ័យល្អសម្រាប់ដាក់បង្កាត់ ក្នុងស្រះបាន ។ ចំពោះត្រីមេពូជទីឡាព្យ៉ា ដែលមានទំងន់ ១០០-១៥០ក្រាម គឺជាទំហំត្រីមេពូជដែលល្អជាងគេ បើសិនជាយើងថែរក្សាគ្រប់គ្រងវាបានល្អ ។ ដង់ស៊ីតេដាក់បង្កាត់ក្នុងស្រះ អាចមានពី 0,៥-១ ក្បាលក្នុង ១ម៉ែត្រការ៉េស្រះ និងដង់ស៊ីតេភេទដាក់បង្កាត់ គឺមាន ញី ២ និង ឈ្មោល ១។ ចំណែកការជ្រើសរើសត្រីមេពូជដាក់បង្កាត់ ត្រូវគោរពទៅតាមមេរៀនដែលបានបញ្ជាក់នៅចំណុច ២.៧ ខាងលើ ។

## ២.៩.២- ការដាក់បង្កាត់ត្រីមេពូជ

ត្រីទីឡាព្យ៉ាធ្វើការបន្តពូជស្ទើររៀងរាល់ខែ កាលបើវាក្លាយជាត្រីមេពូជពេញវ័យល្អ និង មានការគ្រប់គ្រងបានត្រឹមត្រូវតាមបច្ចេកទេស។ ត្រីមេពូជទីឡាព្យ៉ា ជាប្រភេទត្រីថែរក្សាពង និងកូនទើបនឹងញាស់បានយ៉ាងល្អ នៅក្នុងស្រះ។ នេះបានផ្តល់លទ្ធភាពដល់កសិករនៅតាមជនបទ អាចធ្វើការបង្កាត់ ភ្ញាស់ និងបំប៉នកូនត្រីម្សៅទីឡាព្យ៉ា (កូនត្រីតូចៗ)បាន។ ត្រីទីឡាព្យ៉ាជាប្រភេទត្រីមួយងាយស្រួលក្នុងការផលិតកូន ពីព្រោះវាថែរក្សាការពារកូនរបស់វាបានល្អ ដែលប្រភេទត្រីផ្សេងទៀតមិនអាចធ្វើបាន ដោយសារកូនត្រី ក្រោយពេលញាស់ហើយវាងាយងាប់ទៅវិញ ។ ខាងក្រោមនេះ ជាលក្ខណៈនៃការបង្កាត់ ភាស់ពងត្រីទីឡាព្យ៉ាក្នុងស្រះ ប្រភេទត្រី *Oreochromis niloticus*៖

- ក្រោយពេលដាក់ត្រីមេពូជបង្កាត់ក្នុងស្រះ ត្រីទីឡាព្យ៉ានឹងស៊ាំនឹងបរិយាកាសក្នុងទឹកស្រះ រយៈពេលពី ៣-៤ថ្ងៃ
- ក្រោយមក ត្រីឈ្មោលកំណត់រកទីកន្លែងធ្វើសំបុកនៅបាតស្រះ ឬនៅជើងទេរស្រះ ដើម្បីឱ្យត្រីមេចូលពង ។ ត្រីឈ្មោលធ្វើសំបុក ដោយប្រើមាត់របស់វារំលីងដីភក់ រាងជារង្វង់ដែលមានអង្កត់ផ្ចិតពី ២០-៣០ស.ម (សង់ទីម៉ែត្រ) ជម្រៅពី ៥-៨ ស.ម (សូមមើលរូបភាពលេខ ១ ខាងក្រោម)
- រួចត្រីឈ្មោលទាក់ទាញ ត្រីញីឱ្យចូលសំបុក ហើយហែលឆ្វាត់ឆ្វែងចែចង់ជាមួយត្រីញី
- បន្ទាប់មក ត្រីញីក៏ទម្លាក់ពងទៅក្នុងសំបុក ហើយពេលនោះត្រីឈ្មោលក៏បាញ់ស្ពែមទៅលើគ្រាប់ពង
- រួចត្រីញីបឺតយកគ្រាប់ពងរបស់វាចូលក្នុងមាត់ ហើយចាកចេញពីសំបុក (សូមមើលរូបភាពលេខ២-៣)។ ត្រីឈ្មោលបន្តយាមសំបុកពង ហើយទាក់ទាញត្រីញីផ្សេងទៀតឱ្យចូលពងក្នុងសំបុករបស់វា។ ការធ្វើសកម្មភាពទាំងនេះមានរយៈពេលតិចជាង ១ថ្ងៃ។

- ពងត្រីត្រូវបានភ្ញាស់នៅក្នុងមាត់ត្រីមេទីឡាព្យ៉ា រយៈពេលពី ៣-៥ថ្ងៃ។ កូនត្រីម្សៅ (កូនត្រីតូចៗ) ដែលទើបនឹងញាស់ ត្រូវបានត្រីមេរបស់វានៅបន្តតាមថែរក្សារយៈពេលពី ៥-៧ថ្ងៃ បន្ថែមទៀត។ នៅពេលត្រីមេជួបឧបសគ្គ វាហាមាត់របស់វាឱ្យកូនត្រីរត់ចូលក្នុងមាត់ ដើម្បីគេចពីសត្រូវ (សូមមើលរូបភាពលេខ ៤)
- ត្រីមេវាមិនស៊ីអាហារ ក្នុងកំឡុងពេលវាកំពុងភ្ញាស់ពងក្នុងមាត់ និងនៅពេលវាថែរក្សាកូនទើបញាស់
- ប្រមាណ ១សប្តាហ៍ក្រោយមក បន្ទាប់ពីត្រីមេឈប់បណ្តើរកូន ត្រីមេនឹងអាចបន្តពូជសារជាថ្មីថែមទៀត
- កូនត្រីក្រោយពេលត្រីមេចាកចេញពីវា ពួកវាចូលចិត្តហែលជាហ្វូង ដែលងាយស្រួលឱ្យកសិករអាចចាប់វាបានដោយប្រើថ្នងដួស។





រូបភាពទី ១



រូបភាពទី ២



រូបភាពទី ៣



រូបភាពទី ៣



រូបភាពទី ៤

---



ដំណាក់កាលវិវត្តន៍ពងត្រីទីឡាព្យ៉ា ដល់ដំណាក់កាលកូនត្រីម្សៅ



អាយុ ១១ ថ្ងៃ





អាយុ ៧ ថ្ងៃ



## ២.១០- ប្រភេទចំណី និងការផ្តល់ចំណី

កូនត្រីទីឡាព្យ៉ាដែលចាប់បានពីស្រះបង្កាត់ ជាទូទៅមានទំហំខុសគ្នា១ ហើយត្រូវរែងវាដោយប្រើថ្នងដូចក្នុងរូបភាពខាងក្រោម ដើម្បីទទួលបានកូនត្រីមានទំហំប៉ុន១គ្នា មកបំប៉នក្នុងហាប៉ា ឬ ស្រះ ។ វិធីនេះធ្វើឡើងដើម្បីឱ្យកូនត្រីមានការលូតលាស់ល្អក្នុងពេលតែមួយ និងទទួលបានអត្រារស់ខ្ពស់ ជៀសវាងកូនត្រីដែលមានទំហំធំ ដណ្តើមស៊ីចំណីពីកូនត្រីមានទំហំតូច ។



កូនត្រីមានទំហំតូចរត់ចេញពីថ្នង តាមក្រឡាសំណាញ់ នៅសល់កូនត្រីមានទំហំធំ

ចំណីដែលត្រូវផ្តល់ឱ្យកូនត្រីស៊ីត្រូវមានគុណភាពល្អ ។ ចំពោះកសិករផលិតកូនត្រីពូជនៅតាមជនបទ អាចឱ្យប្រើកន្ទក់ លាយជាមួយម្សៅត្រី ដែលជាចំណីល្អបំផុតសម្រាប់ថែបំប៉នកូនត្រី ។ ធាតុផ្សំនៃចំណីទាំងពីរបែបនេះត្រូវមានគុណភាពល្អ ហើយត្រូវលាយយកកន្ទក់ ១ គ.ក្រ ជាមួយ ម្សៅត្រី ៣ គ.ក្រ ។

សម្រាប់កូនត្រីមានទំហំតូច ត្រូវផ្តល់ចំណីដូចខាងក្រោម ៖

- ផ្តល់ចំណីឱ្យស៊ីពី ៤-៦ដង ក្នុង១ថ្ងៃ
- ចំណីផ្សំ (កន្ទក់ ១គ.ក្រ និងម្សៅត្រី ៣គ.ក្រ) ផ្តល់ឱ្យកូនត្រីស៊ីចំនួន ១០០.០០០ក្បាល។ បរិមាណចំណីនេះអាចប្រែប្រួលទៅតាមការស៊ីចំណីជាក់ស្តែងរបស់ត្រី
- ដង់ស៊ីតេដាក់កូនត្រីបំប៉ន អាចដាក់ ១.០០០ ក្បាល ក្នុង ១ ម៉ែត្រការ៉េស្រះ ឬ ហាប៉ា
- ក្រោយពីបំប៉នបានរយៈពេល ១ ខែ កូនត្រីមានទំហំធំជាងមុន ហើយត្រូវរំលែកវាយកទៅបំប៉នក្នុងស្រះផ្សេងទៀត ដោយបន្ថយបរិមាណកូនត្រីដាក់បំប៉ន ដើម្បីឱ្យកូនត្រីមានការលូតលាស់ល្អ
- ចំពោះកូនត្រីទីឡាព្យ៉ា ដែលមានទំហំ ១-២ស.ម ប្លង់តុងជាចំណីសំខាន់របស់វា ។



កំទេចត្រីហាលក្រៀមសម្រាប់បុកលាយជាមួយកន្ទក់





ការផ្តល់ចំណីបំប៉នកូនត្រីនៅក្នុងស្រះ

ចំពោះកូនត្រីមានទំហំធំ (ពី ២ស.មឡើង) ត្រូវផ្ដល់ចំណីដូចខាងក្រោម ៖

- ផ្ដល់ចំណីឱ្យស៊ីពី ៣ ដង ក្នុង១ថ្ងៃ
- ចំណីផ្សំ (កន្ទក់ ១គ.ក្រ និងម្សៅត្រី ៣គ.ក្រ) ផ្ដល់ឱ្យកូនត្រីស៊ីចំនួន ៣០.០០០ក្បាល។ បរិមាណចំណីនេះអាចប្រែប្រួលទៅតាមការស៊ីចំណីជាក់ស្ដែងរបស់ត្រី។
- ដង់ស៊ីតេដាក់កូនត្រីបំប៉ន អាចដាក់ ៣០០ក្បាល ក្នុង ១ម៉ែត្រការ៉េស្រះ ឬ ហាប៉ា
- ក្រោយពីបំប៉នបានរយៈពេល ១ខែ កូនត្រីមានទំហំធំជាងមុន ហើយត្រូវវិលែកវាយកទៅបំប៉នក្នុងស្រះផ្សេងទៀត ដោយបន្ថយបរិមាណកូនត្រីដាក់បំប៉ន ដើម្បីឱ្យកូនត្រីមានការលូតលាស់ល្អ។
- ប្លង់តុងនៅតែជាចំណីសំខាន់ ក្នុងការថែបំប៉នកូនត្រី ។

ចំពោះត្រីមេពូជ ត្រូវផ្ដល់ឱ្យស៊ីក្នុងអត្រាពី ១-២ភាគរយនៃទំងន់ដងខ្លួនត្រីសរុប សម្រាប់រយៈពេល ១ថ្ងៃ ហើយត្រូវផ្ដល់ឱ្យស៊ីពី ២-៣ដង ក្នុងនោះត្រូវមានកំរិតជាតិប្រូតេអ៊ីន ៣០-៣៥ភាគរយ ។ ក្រៅពីនេះត្រីមេពូជអាចស៊ីចំណីធម្មជាតិដែលមាននៅក្នុងស្រះ ។ បរិមាណចំណីនេះអាចត្រូវកាត់បន្ថយនៅពេលត្រីមេពូជចាប់ផ្ដើមបន្តពូជ ។

## ២.១១- ប្រភេទជី និងការផ្ដល់ជី

ចំពោះស្រះបំប៉នកូនត្រីម្សៅ (កូនត្រីតូចៗ) ជីសរីរាង្គ ពិសេស ជីលាមកសត្វ មិនត្រូវឱ្យប្រើក្នុងស្រះបំប៉នកូនត្រីពូជទេ ពីព្រោះក្រោយពេលដាក់ជីសរីរាង្គនេះ វាកើតសត្វល្អិត និងមមូងជាច្រើននៅក្នុងស្រះ ដែលជាហេតុផលមិនល្អ ធ្វើឱ្យកូនត្រីម្សៅមានអត្រារស់ទាប ព្រោះសត្វល្អិតទាំងនេះសម្លាប់កូនត្រីតូចៗ ។ ដូចនេះ កូនត្រីម្សៅត្រូវដាក់បំប៉នក្នុងស្រះដែលកុំឱ្យមានប្រើជីសរីរាង្គ គឺ ប្រើតែជីគីមី ។ ក្នុងអំឡុងពេលកូនត្រីម្សៅនៅតូច ត្រូវបំប៉នវាឱ្យស៊ីចំណីសិប្បនិម្មិត ដូចដែលបានរៀបរាប់ក្នុងមេរៀនទី ២.១០ ខាងលើ ។

ក្នុងការចិញ្ចឹមត្រី ការប្រើប្រាស់ជី ត្រូវបានគេយកមកអនុវត្ត នៅដំណាក់កាល ២ យ៉ាង ៖ ១-នៅពេលរៀបចំស្រះ និងទី២- នៅក្រោយពេលដាក់កូនត្រីចិញ្ចឹម ។ ពណ៌សម្បុរទឹកស្រះ ជាសញ្ញាសំគាល់យ៉ាងសំខាន់ថាតើ ទឹកស្រះនោះត្រូវការផ្ដល់ជីដែរឬទេ ? ជាទូទៅទឹកស្រះត្រូវការផ្ដល់ជីបន្ថែម នៅក្រោយពេលដាក់កូនត្រីបាន ១សប្ដាហ៍ ។ ប៉ុន្តែបើទឹកស្រះមិនមានប្រែពណ៌ទេ ពោលគឺនៅមានពណ៌បៃតងដដែល នោះការផ្ដល់ជីបន្ថែមមិនត្រូវបានអនុញ្ញាតឡើយ។ តែទោះជាយ៉ាងណាក៏ដោយ ក្នុងករណីខ្លះនៅពេលទឹកស្រះមានពណ៌ល្អក់ ក៏អាចមានសម្បូរសត្វល្អិតប្លង់តុងបានដែរ ។ ដូចនេះកសិករត្រូវធ្វើការត្រួតពិនិត្យមើល បរិមាណសត្វល្អិតប្លង់តុង ដោយប្រើប្រាស់ក្រមា ឬថ្នងចុះដួសទឹកនៅជ្រុងណាមួយនៃស្រះ (សូមមើលរូបភាពខាងក្រោម)។ បើឃើញថា មានសត្វល្អិតប្លង់តុងតិច នោះចាំបាច់តម្រូវឱ្យមានការផ្ដល់ជីបន្ថែម ។



ការត្រួតពិនិត្យវត្តមានសត្វល្អិតប្លង់តុងនៅក្នុងទឹកស្រះ



រូបភាពសត្វល្អិតប្លង់តុងនៅក្នុងកែវ

ការប្រើប្រាស់ជីក្នុងស្រះត្រី មិនត្រឹមតែបង្កើនចំណីធម្មជាតិប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងកែលំអមជ្ឈដ្ឋានទឹកស្រះឱ្យបានល្អ សម្បូរខ្យល់អុកស៊ីសែន និងកាត់បន្ថយបរិមាណឧស្ម័នពុលដែលមានក្នុងស្រះត្រីទៀតផង ។

បើកសិករប្រើជីបន្ថែមមិនបានត្រឹមត្រូវ នោះនឹងធ្វើឱ្យត្រីពុល និងអាចងាប់ឆាប់រហ័ស ។ ដូចបានរៀបរាប់នៅក្នុងមេរៀនរៀបចំស្រះ ប្រភេទជីត្រូវប្រើមាន ២ប្រភេទគឺ ជីធម្មជាតិ ឬជីសរីរាង្គ (ជីលាមកសត្វ និងជីបៃតង) និងជីគីមី ឬជីអសរីរាង្គ (មានជីអ៊ុយរ៉េ និងជីដេអាប៉េ) ដែលជាប្រភេទជីគ្រាប់មានពណ៌ស និងពណ៌ខ្មៅ។ ក្នុងករណីចង់ប្រើជីបន្ថែមជាប្រភេទជីគីមី កសិករត្រូវយកជីអ៊ុយរ៉េ ៣០០ក្រាម លាយជាមួយជីដេអាប៉េ ១០០ក្រាម កូរជាមួយទឹកក្នុងធុងឱ្យរលាយគ្រាប់អស់សិន ទើបយកទៅបាចលើផ្ទៃទឹកស្រះ ដើម្បីកុំឱ្យត្រីចាប់យកគ្រាប់ជីស៊ីផ្ទាល់ ដែលនឹងធ្វើឱ្យត្រីងាប់ភ្លាម ។ បើកសិករពុំមានលទ្ធភាពប្រើជីគីមី គឺអាចប្រើជីធម្មជាតិ ឬជីសរីរាង្គ ក្នុងបរិមាណតិចតួចបំផុត គឺតិចជាងបរិមាណជីប្រើពេលរៀបចំស្រះ ដើម្បីជៀសវាងការប្រើជីជ្រុលហួសកំរិត ដែលធ្វើឱ្យទឹកស្រះពុល ខ្យល់អុកស៊ីសែនក្នុងស្រះធ្លាក់ចុះ បរិមាណឧស្ម័នពុលកើនឡើង និងធ្វើឱ្យត្រីងាប់ភ្លាម ។ ប៉ុន្តែចំពោះស្រះបំប៉នកូនត្រីម្សៅ កសិករគួរប្រើជីគីមី ទើបល្អ ។

ចំពោះការប្រើជីធម្មជាតិ កសិករត្រូវអនុវត្តតាមវិធីសាស្ត្រដូចខាងក្រោម ៖

- ជីករណ្តៅមួយមានទំហំបណ្តោយ ២-៣ម ទទឹង ១-២ ម ជម្រៅ ០,៥ម ឬ ជីករណ្តៅតូចមួយនៅលើភ្លឺស្រះ ដូចរូបខាងក្រោម រួចដាក់លាមកសត្វគោ ក្របី ឬ ជ្រូក មាន់ ទា ត្រាំទឹកក្នុងរណ្តៅនោះ ។
- ទុកវារយៈពេលពី ៣ ទៅ ៥ថ្ងៃ បន្ទាប់មកកសិករអាចដួសទឹកជីក្នុងរណ្តៅនោះ ដាក់ចូលក្នុងស្រះចិញ្ចឹមត្រី ។
- វិធីនេះកាត់បន្ថយបានការប្រើប្រាស់បរិមាណអុកស៊ីសែន និង បន្ថយជាតិឧស្ម័នពុលនៅក្នុងស្រះចិញ្ចឹមត្រី ។




វិធីសាស្ត្រសមស្របនៃការប្រើប្រាស់ជីធម្មជាតិបន្ថែម ក្នុងស្រះចិញ្ចឹមត្រី

ជាទូទៅការប្រើប្រាស់ជីបន្ថែម ក្រោយពេលដាក់ត្រីបំប៉ន ឬ ត្រីចិញ្ចឹម ត្រូវអនុវត្តនៅពេលមានពន្លឺថ្ងៃបានគ្រប់គ្រាន់ព្រោះពេលនោះទឹកក្នុងស្រះសម្បូរខ្យល់អុកស៊ីសែន ដែលធ្វើឱ្យត្រីមិនពុល ក្រោយពេលដាក់ជី ។

ប្រសិទ្ធិភាពនៃការប្រើប្រាស់ជី គឺអាស្រ័យនឹងកត្តាដូចខាងក្រោម ៖

- សីតុណ្ហភាពទឹកក្នុងស្រះចិញ្ចឹមត្រីមានពី ២៥ -៣០អង្សាសេ
- pH ក្នុងទឹកស្រះមានពី ៦,៥ - ៩

- ❑ កំរិតរលាយអុកស៊ីសែនមានយ៉ាងតិចពី ៣-៧ មីលីក្រាម ក្នុង១ លីត្រទឹក
- ❑ ប្រភេទដីស្រះ ភាគច្រើនជាប្រភេទដីឥដ្ឋ
- ❑ លក្ខណៈស្រះ ធំទូលាយ  មានទឹកច្រើន  គ្មានដើមឈើជុំវិញស្រះ  និងមានជើងទេរ ។

ខាងក្រោមនេះ ជាការប្រៀបធៀបកំរិតជាតិអាសូត ដែលមាននៅក្នុងជីលាមកសត្វផ្សេងៗគ្នា




| | លាមកមាន់ | លាមកជ្រូក | លាមកពពែ | លាមកគោ ក្របី |
|---|---|---|---|---|
| N (%) | 4.5 | 1.9 | 1.8 | 1.1 |
| P (%) | 1.8 | 1.5 | 0.4 | 0.3 |
| K (%) | 1.4 | 1.9 | 0.9 | 1.4 |

**ឯកសារយោង**

- Brooks & Maluwa (1997) for chicken & pig manure;
- Kerr (1999) for goat manure;
- Straaten (1999) for cattle manure.

## ២.១២- ការគ្រប់គ្រងស្រះ

ជាទូទៅ វិធីនៃការគ្រប់គ្រងស្រះនៅក្នុងសៀវភៅគោលការណ៍ណែនាំបច្ចេកទេសនេះ  គឺដូចគ្នានឹងសៀវភៅគោលការណ៍ណែនាំបច្ចេកទេស ស្តីពី បច្ចេកទេសចិញ្ចឹមត្រីជាលក្ខណៈគ្រួសារ ដែលបានរៀបរាប់រួចហើយ ។ តែទោះជាយ៉ាងណាក៏ដោយ  បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះ  នៅមានចំណុចសំខាន់ៗនៃការគ្រប់គ្រងស្រះផលិតកម្មកូនត្រីពូជ  បន្ថែមទៀតដូចខាងក្រោម ៖

- ❑ ទឹកស្រះត្រូវរក្សាឱ្យមានលក្ខខណ្ឌបរិយាកាសល្អ ដើម្បីធានាឱ្យត្រីមានសុខភាពរឹងមាំ និងលូតលាស់បានឆាប់រហ័ស (សូមមើលតារាងខាងក្រោម)
- ❑ ទឹកស្រះត្រូវរក្សាឱ្យមានគុណភាពល្អ ឬ រក្សាឱ្យមានសម្បូរចំណីធម្មជាតិ ដោយត្រូវយកចិត្តទុកដាក់ក្នុងការដាក់ជីបន្ថែមឱ្យបានទៀងទាត់ពេលវេលា  និងត្រឹមត្រូវតាមបច្ចេកទេស ដូចបានបញ្ជាក់ក្នុងមេរៀនខាងលើ ចំណុចទី ២.១១

- ត្រូវឧស្សាហ៍ត្រួតពិនិត្យគុណភាពទឹកស្រះជាប់ជាប្រចាំ ដោយប្រើ Secchi disk (ថាសត្រួតពិនិត្យគុណភាព ទឹក) (សូមមើលការណែនាំនៅចំណុចមេរៀនទី ២.៦.៣)
- ត្រូវឧស្សាហ៍ត្រួតពិនិត្យមើលបរិមាណសត្វល្អិតប្លង់តុងក្នុងទឹកស្រះ ដោយប្រើថ្នង ឬក្រមា
- ត្រូវឧស្សាហ៍ជួសកូនត្រីទីឡាព្យ៉ាមកបំប៉នក្នុងហាប៉ា
- ត្រូវយកចិត្តទុកដាក់ រកមូលហេតុនៃបញ្ហាកើតមានឡើង និងព្យាយាមដោះស្រាយបញ្ហា
- ត្រូវឧស្សាហ៍អង្កេតមើលសកម្មភាពត្រី ក្រែងលោកើតមានជំងឺ
- ត្រូវយកចិត្តទុកដាក់ ការពារកុំឱ្យត្រីកើតមានជំងឺ ។

## ២.១២.១- ការត្រួតពិនិត្យគុណភាពទឹក

| ចំណុចវិភាគគុណភាពទឹក | កំរិតចន្លោះគុណភាពទឹក ដែលត្រីរស់នៅបាន | ចំណុចគុណភាពទឹកដែលល្អ |
|---|---|---|
| - សីតុណ្ហភាព (អង្សារសេប | ពី ៨-៤២ (អង្សារសេប | ពី ២៨-៣២ (អង្សារសេប |
| - កំហាប់អំបិល (ភាគពាន់) | តិចជាង ២០-៣៥ ភាគពាន់ | ពី ០-៥ ភាគពាន់ |
| - កំរិតរលាយអុកស៊ីសែន (មីលីក្រាមក្នុង ១លីត្រទឹកប | ពី ០,១-៣ | ធំជាង ៥ មីលីក្រាមក្នុង ១លីត្រទឹក |
| - ប៉េហាស់ (pH) | ពី ៤-១១ | ពី ៦,៥-៨,៥ |
| - កំរិតរលាយឧស្ម័នអាម៉ូនីញ៉ាក់ (មីលីក្រាមក្នុង ១លីត្រទឹកប ដែលធ្វើឱ្យត្រីងាប់ | ធំជាង ២០ | តិចជាង ០,០២ (មីលីក្រាមក្នុង ១លីត្រទឹកប |
| - កំរិតរលាយឧស្ម័នកាបូនិច (មីលីក្រាមក្នុង ១លីត្រទឹកប ដែលធ្វើឱ្យត្រីងាប់ | ធំជាង ៧៣ (មីលីក្រាមក្នុង ១លីត្រទឹកប | |

## ២.១២.២- ការការពារជម្ងឺ ក្នុងផលិតកម្មកូនត្រីពូជ

ការការពារកុំឱ្យមានជំងឺត្រី ក្នុងពេលចិញ្ចឹមត្រី ជាវិធានការមួយល្អប្រសើរជាងការព្យាបាលជំងឺ ។ ដើម្បីការពារកុំឱ្យមានជំងឺត្រី ត្រូវយកចិត្តទុកដាក់វិធានការការពារមួយចំនួន ដូចខាងក្រោមនេះ ៖

- ជ្រើសរើសត្រីមេពូជ និងកូនត្រី ដែលមានសកម្មភាពខ្លាំង ធន់នឹងជំងឺ មានសុខភាពរឹងមាំ និងធន់នឹងការប្រែប្រួលសីតុណ្ហភាព
- ត្រូវថែរក្សា បំប៉នត្រីមេពូជ និងកូនត្រី ឱ្យបានល្អត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ត្រូវដាក់បំប៉ន ឬបង្កាត់ ត្រីមេពូជ ឱ្យត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ត្រូវរៀបចំស្រះឱ្យបានល្អ តាមលក្ខណៈបច្ចេកទេស
- ត្រូវផ្តល់ចំណីមានគុណភាពល្អ ឱ្យបានគ្រប់គ្រាន់ និងទៀងទាត់ពេលវេលា
- ប្រភពទឹកយកមកចិញ្ចឹម ត្រូវស្អាត ល្អ គ្មានជាតិពុល
- ត្រូវរៀបចំដឹកជញ្ជូនកូនត្រី ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស
- ប្រភពចំណីធម្មជាតិដែលយកមកឱ្យត្រីស៊ី ត្រូវពិនិត្យកុំឱ្យមានជាតិពុល
- ត្រូវគ្រប់គ្រងទឹកស្រះឱ្យបានល្អជាប់ជានិច្ច ។

ទាំងអស់នេះជាមូលដ្ឋានគ្រឹះនៃការការពារជំងឺត្រីកុំឱ្យកើតមាន ក្នុងអំឡុងពេលផលិតកម្មកូនត្រីពូជ ។ ជំងឺត្រីភាគច្រើនកើតមានក្នុងរដូវភ្លៀង ឬ រដូវត្រជាក់ ។ ពេលជួបប្រទះនឹងជំងឺ កសិករភាគច្រើនអនុវត្តការព្យាបាល តាមវិធីសាស្ត្របុរាណ ដូចជា ការប្រើកំបោរ ជាមួយប៉ូតាស្យូមប៉ែម៉ង់កាណាត ឬ ប្រើជាមួយអំបិលជាដើម ។

## ២.១២.៣- ការគ្រប់គ្រងស្រះបង្កាត់

គោលបំណងនៃការគ្រប់គ្រងស្រះបង្កាត់ គឺដើម្បីបង្កើនផលិតផលកូនត្រីពូជ ដោយផ្អែកលើការគ្រប់គ្រងឱ្យបានត្រឹមត្រូវតាមបច្ចេកទេស ។ កូនត្រីទីឡាព្យ៉ាដែលប្រមូលចាប់ពីស្រះបង្កាត់ ដែលពុំមានការគ្រប់គ្រងបានល្អ ជាទូទៅតែងតែមានទំហំខុសៗគ្នា ។ បញ្ហានេះនឹងធ្វើឱ្យផលិតផលកូនត្រីពូជ ពុំបានទទួលផលដូចក្នុងផែនការដែលបានគ្រោងទុក ពីព្រោះវាបណ្ដាលមកពីកូនត្រីទីឡាព្យ៉ាដែលមានទំហំធំ ស៊ីកូនត្រីទីឡាព្យ៉ាដែលមានទំហំតូច ដូចនេះជាលទ្ធផលកសិករនឹងទទួលបានទិន្នផលកូនត្រីទាប។ ដើម្បីដោះស្រាយបញ្ហានេះ កសិករត្រូវខុសុប្ញាហ៍ត្រួតពិនិត្យមើលទំហំកូនត្រីនៅក្នុងស្រះ បង្កាត់ និងស្រះបំប៉ន បើមានទំហំខុសគ្នា ត្រូវខុសុប្ញាហ៍ដួសចាប់វាមករែងយកទំហំប៉ុនគ្នាមកដាក់បំប៉នជាមួយគ្នា (សូមមើលមេរៀនខាងក្រោម ២.១៣) ធ្វើយ៉ាងនេះដើម្បីឱ្យកូនត្រីមានអត្រារស់ច្រើន និងបំប៉នឆាប់បានធំធាត់ល្អ ។ ម្យ៉ាងទៀត ស្រះបង្កាត់អាចខ័ណ្ឌចែកដោយព្រួលឬស្សីជាពីរផ្នែកស្មើគ្នា ឬ១ផ្នែកមានផ្ទៃ ១ភាគ៣ និងមួយផ្នែកទៀតមានផ្ទៃ ២ភាគ៣ សម្រាប់ដាក់ត្រីមេពូជបង្កាត់។ ព្រួលឬស្សីនេះត្រូវក្រងឱ្យមានចន្លោះប្រហោងស្មើគ្នាពី ១-១,៥ស.ម ដើម្បីឱ្យកូនត្រីទីឡាព្យ៉ាអាចឆ្លងកាត់បាន។ ការរៀបចំធ្វើរបៀបនេះ គឺដើម្បីងាយស្រួលក្នុងការប្រមូលផលកូនត្រីទីឡាព្យ៉ាក្នុងស្រះ (ផ្នែកមិនដាក់ត្រីមេពូជ) ដោយការអូសអួន មិនរំខានដល់ត្រីមេពូជទីឡាព្យ៉ាក្នុងស្រះឡើយ។

ជារៀងរាល់ឆ្នាំ ស្រះផលិតកូនត្រីពូជត្រូវរៀបចំសំអាតឡើងវិញ ដោយបូមទឹកពង្រីងចាប់ត្រីកាចចេញ រួចដាក់កំបោរ ជី ដូចក្នុងមេរៀន ២.៦ ខាងលើបានបញ្ជាក់ បន្ទាប់មកត្រូវរៀបចំដាក់ត្រីមេពូជចូលក្នុងស្រះបង្កាត់វិញ ។ ធ្វើដូចនេះនឹងនាំឱ្យស្រះមានគុណភាពល្អ ដោយផ្លាស់ទឹកចាស់ចេញ ប្ដូរយកទឹកថ្មី សម្បូរចំណីធម្មជាតិ បរិមាណខ្យល់អុកស៊ីសែនក្នុងស្រះកើនឡើង និងបរិមាណឧស្ម័នពុលថយចុះ។ ម្យ៉ាងទៀតបើសិនជាកសិករមានត្រីមេពូជទីឡាព្យ៉ាថ្មីៗ ដែលមានគុណភាពល្អ កសិករគួរដូរត្រីមេពូជទីឡាព្យ៉ាចាស់ៗចេញ ហើយដាក់ជំនួសត្រីមេពូជទីឡាព្យ៉ាថ្មីវិញ ដើម្បីបង្កើនផលិតផលកូនត្រីពូជនៅឆ្នាំបន្តបន្ទាប់។

## ២.១២.៤- ការគ្រប់គ្រងស្រះបំប៉នកូនត្រី

ក្រៅពីការគ្រប់គ្រងស្រះបង្កាត់ កសិករក៏ត្រូវយកចិត្តទុកដាក់គ្រប់គ្រងស្រះបំប៉នកូនត្រីពូជផងដែរ ដើម្បីឱ្យផលិតបានបរិមាណកូនត្រីពូជបានច្រើន។ ដើម្បីសម្រេចបានដូចនេះ កសិករត្រូវយកចិត្តទុកដាក់ចំណុចសំខាន់ៗ ដូចខាងក្រោម៖

- ស្រះបំប៉នកូនត្រីត្រូវរៀបចំឱ្យបានល្អ ត្រឹមត្រូវតាមបច្ចេកទេស គឺត្រូវរៀបចំស្រះឱ្យមានទឹកពណ៌បៃតង និងគ្មានត្រីកាច។ ក្នុងករណីមានត្រីកាចច្រើននៅជុំវិញស្រះបំប៉ន កសិករត្រូវយកសំណាញ់មកបាំងជុំវិញស្រះបំប៉នកូនត្រីនោះ។
- កូនត្រីមុននឹងដាក់បំប៉នក្នុងស្រះ ឬ ហាប៉ា ត្រូវរែងឱ្យមានទំហំប៉ុនគ្នា ទើបអាចដាក់បំប៉នជាមួយគ្នាបាន
- ត្រូវផ្ដល់ចំណីដែលមានគុណភាពល្អ ឱ្យបានគ្រប់គ្រាន់ និងទៀងទាត់ពេលវេលា
- ក្រោយពីបំប៉នបានរយៈពេល ១ខែ កូនត្រីត្រូវរំលែកទៅដាក់បំប៉នក្នុងស្រះ ឬហាប៉ាផ្សេងទៀត ដោយបន្ថយបរិមាណកូនត្រីដាក់ចិញ្ចឹម (សូមមើលមេរៀន ២.១០)។
- ស្រះបំប៉ន ត្រូវការពារកុំឱ្យលិចទឹក កុំឱ្យមានត្រីកាចចូល និងការពារកុំឱ្យមានកើតជំងឺ

- ជារៀងរាល់ឆ្នាំ ស្រះបំប៉នត្រូវរៀបចំបូមទឹកសំអាតស្រះ ដោយអនុវត្តតាមបច្ចេកទេសដែលបានរៀបរាប់ក្នុងមេរៀនខាងលើ។

## ២.១៣- ការប្រមូលផលកូនត្រីពូជ

ក្រោយពីការដាក់ត្រីមេពូជទីឡាព្យ៉ា ក្នុងស្រះបង្កាត់ប្រមាណពី ៤-៦សប្តាហ៍ កសិករអាចចាប់ផ្តើមប្រមូលផលកូនត្រីទីឡាព្យ៉ា ដោយការអូសអួន ដែលមានទំហំក្រឡាសំណាញ់ពី ៦-១២មីលីម៉ែត្រ អាស្រ័យនឹងទំហំកូនត្រីដែលចង់បាន (សូមមើលរូបភាពខាងក្រោម)។ ត្រីមេពូជទីឡាព្យ៉ាដែលចាប់បានជាមួយអួនអូស ត្រូវប្រញាប់ចាប់វា លែងចូលក្នុងស្រះបង្កាត់វិញ (ក្នុងករណីស្រះបង្កាត់មិនបានខ័ណ្ឌជាពីរ)។ សកម្មភាពប្រមូលផលនេះ គួរធ្វើនៅរៀងរាល់ពេល ១-២ សប្តាហ៍ម្តង។ កូនត្រីដែលចាប់បានមានទំហំមិនដូចគ្នាទេ ដូចនេះវាចាំបាច់តម្រូវឱ្យរែងយកទំហំប៉ុនៗគ្នា ទៅដាក់ បំប៉នក្នុងស្រះ ឬ ហាប៉ារហូតទទួលបានកូនត្រីពូជមានទំហំធំ ។



អូសអួនចាប់កូនត្រីទីឡាព្យ៉ាពីស្រះបង្កាត់ពូជ



រួចយកមកដាក់បំប៉នក្នុងស្រះ និង ហាប៉ា

ក្នុងករណីកសិករគ្មានអួនអូស កសិករអាចប្រើថ្នងដួសចាប់កូនត្រីក៏បាន ដោយត្រូវឧស្សាហ៍ចាប់វានៅតាមជ្រុងស្រះ រួចយកមកដាក់បំប៉នក្នុងស្រះ ឬ ហាប៉ា រហូតដល់កូនត្រីមានទំហំធំ (សូមមើលបន្ថែមនៅមេរៀនចំណុច ២.៩)។ ហាប៉ាដែលបំប៉នកូនត្រី អាចមានទំហំប៉ុនណាក៏បាន។ ជាធម្មតា ហាប៉ាច្រើនមានទំហំ បណ្តោយ ៣ម៉ែត្រ ទទឹង ២ម៉ែត្រ និងជម្រៅ ១ម៉ែត្រ។ បរិមាណកូនត្រីដែលផលិតបាន គឺអាស្រ័យនឹងការគ្រប់គ្រងរបស់កសិករ។ បើកសិករគ្រប់គ្រងបានល្អ អាចទទួលផលបាន ១.០០០ក្បាល (ទំហំជាមធ្យម ១ក្រាមក្នុង១ក្បាល) ក្នុងស្រះទំហំ ១០០ម$^២$ រយៈពេល ១សប្តាហ៍ ឬ អាចទទួលផលបាន ៣០០ក្បាល (ទំហំជាមធ្យម ៥- ១៥ក្រាមក្នុង ១ក្បាល) ហើយអាចធ្វើបាន ២ដង ក្នុង១ ឆ្នាំ ។

ម្យ៉ាងទៀត ចំពោះកសិករមានស្រះតែមួយ កំពុងចិញ្ចឹមត្រីទីឡាព្យ៉ាតែមួយប្រភេទ ឬ ចិញ្ចឹមលាយជាមួយត្រីប្រភេទផ្សេងទៀត ក្រោយរយៈពេលចិញ្ចឹមបាន ៦ខែ ត្រីមេពូជទីឡាព្យ៉ាបានផលិតកូនត្រី ហើយយើងនឹងឃើញវាហែលជាហ្វូងនៅតាមជ្រុងស្រះ ។ ក្នុងករណីនេះ កសិករអាចដួសចាប់វាដោយប្រើថ្នង មកបំប៉នក្នុងហាប៉ា (សូមមើលរូបភាពខាងក្រោម)។ ជាទូទៅ កសិករត្រូវឧស្សាហ៍ចាប់វានៅរៀងរាល់ពេលព្រឹកព្រលឹម ដែលត្រីមេទីឡាព្យ៉ាភាគច្រើនតែងតែបណ្តើរកូននៅពេលព្រឹក ដើម្បីស្រូបយកខ្យល់អុកស៊ីសែននៅលើផ្ទៃទឹកស្រះ ។ ពេលនេះកសិករមានលទ្ធភាពអាចចាប់កូនត្រីដោយប្រើថ្នងមកបំប៉នក្នុងហាប៉ាបាន។ កសិករអាចធ្វើរបៀបនេះ បានច្រើនដង ឬពី ៣-៤ដង ក្នុង១ខែ ដើម្បីចាប់កូនត្រីទីឡាព្យ៉ាឱ្យអស់។ បរិមាណកូនត្រីម្សៅ (កូនត្រីតូចៗ) និងកូនត្រីធំ ដែលផលិតបានពីស្រះចិញ្ចឹមត្រីសាច់ ជាទូទៅមានចំនួន

តិចតួច ដោយសារមានត្រីច្រើនប្រភេទចិញ្ចឹមក្នុងស្រះ ហើយប្រភេទខ្លះស៊ីកូនត្រីទីឡាព្យ៉ា ។ បើកសិករគ្រប់គ្រងបានល្អ គាត់អាចផលិតកូនត្រីទីឡាព្យ៉ាបានទាំងតូចទាំងធំ ២.០០០-៣.០០០ក្បាល ក្នុង ១០០ម² ក្នុងរយៈពេលចិញ្ចឹមត្រីសាច់ពី ៨-១០ ខែ ។ ក្នុងកំឡុងពេលបំប៉នកូនត្រីក្នុងហាប៉ា កសិករត្រូវឧស្សាហ៍ដុសលាងហាប៉ា ដើម្បីឱ្យសត្វល្អិតប្លង់តុងដែលមានក្នុងស្រះអាចចូលទៅក្នុងហាប៉ាបំប៉នកូនត្រីបាន ហើយត្រូវឧស្សាហ៍ដួសសត្វល្អិតប្លង់តុងពីស្រះមកដាក់ឱ្យកូនត្រីស៊ីក្នុងហាប៉ា ដើម្បីឱ្យកូនត្រីឆាប់ធំធាត់រហ័ស (សូមមើលរូបភាពខាងក្រោម)។





ការប្រមូលផលកូនត្រីឱ្យបានទៀងទាត់ពេលវេលាពីស្រះបង្កាត់ នឹងផ្តល់ផលប្រយោជន៍ដូចខាងក្រោម ៖

- ផលិតកូនត្រីពូជទីឡាព្យ៉ាបានច្រើន
- កូនត្រីដែលមានទំហំតូចមានអត្រារស់ច្រើន ពីព្រោះស្រះបង្កាត់អាចមានត្រីកាចស៊ីកូនត្រី
- កូនត្រីដែលប្រមូលចាប់បានពីស្រះបង្កាត់ មានទំហំប៉ុនៗគ្នា
- កូនត្រីដែលមានទំហំប៉ុនគ្នា ដោយការប្រមូលផលបានទៀងទាត់ ឬ ដោយការរែងយកទំហំប៉ុនគ្នា គឺមានអត្រារស់ច្រើន និងមានការលូតលាស់ឆាប់រហ័ស។

ក្នុងការងារអនុវត្ត ការប្រមូលផលកូនត្រីពីស្រះបង្កាត់ តែងតែជួបប្រទះគុណវិបត្តិខ្លះៗ ដូចជា ត្រីមេពូជអាចរបួស ឬ រលាត់ស្បែក និងធ្វើឱ្យទឹកស្រះល្អក់ ក្នុងករណីស្រះបង្កាត់ពូជមិនបានខ័ណ្ឌចែកជា ២ផ្នែកដោយព្រួលឬស្សីដែលមានប្រហោងពី ១-១,៥ស.ម។ ដើម្បីជៀសវាងបញ្ហានេះ កសិករគួរតែព្យាយាមប្រមូលផលកូនត្រី ដោយការអូសអួនយឺតៗ និងប្រញាប់ចាប់ត្រីមេពូជចេញពីអួន លែងចូលស្រះវិញដោយកាន់ថ្នមៗ ។

## ២.១៤- ការចាប់លក់កូនត្រីពូជ

ដូចបានរៀបរាប់ខាងលើ អំពីវិធីផ្តល់ចំណីឱ្យត្រី ក្នុងមេរៀនទី ២.១០ និងរបៀបប្រមូលផលកូនត្រីពីស្រះបង្កាត់ (មេរៀនទី ២.១៣ ) នឹងទទួលបានបរិមាណកូនត្រីពូជច្រើន ដែលមានទំហំប៉ុនៗគ្នា ។ កូនត្រីដែលមានទំហំខុសគ្នាត្រូវដាក់ក្នុងហាប៉ា ឬ ស្រះផ្សេងៗគ្នា ដើម្បីងាយស្រួលក្នុងការថែបំប៉ន និងចាប់លក់ ។ កូនត្រីដែលបានរៀបចំដាក់ក្នុងហាប៉ាដើម្បីលក់ ត្រូវអនុវត្តតាមរបៀបដូចខាងក្រោម ៖

- មិនត្រូវផ្តល់ចំណីឱ្យកូនត្រីស៊ី ១ថ្ងៃ មុនពេលចាប់លក់ ដើម្បីកុំឱ្យកូនត្រីងាប់ច្រើននៅពេលដឹកជញ្ជូន
- ត្រូវឧស្សាហ៍សង្កេតមើលកូនត្រីក្នុងស្រះ ឬ ហាប៉ា បើមានឃើញកូនត្រីណាមានអាការៈឈឺ កសិករត្រូវចាប់វាចេញជាបន្ទាន់ ដើម្បីជៀសវាងឆ្លងទៅកូនត្រីដទៃទៀត
- បើកូនត្រីត្រូវដឹកជញ្ជូនផ្លូវឆ្ងាយ ត្រូវវេចខ្ចប់ដោយថង់ប្លាស្ទិក ដែលមានទំហំ ៨០ស.ម x៦០ស.ម ហើយអាចដាក់កូនត្រីបានពី ៣០០- ៥០០ក្បាល ក្នុង ១ថង់ (កូនត្រីមានទំហំ ៥ស.ម) អាស្រ័យទៅនឹងចំងាយផ្លូវត្រូវដឹក

- ទឹកដែលដាក់ក្នុងថង់ ត្រូវយកចេញពីស្រះដែលកូនត្រីរស់នៅ
- ពេលព្រឹកជាពេលវេលាសមស្រប សម្រាប់ចាប់កូនត្រីលក់ ។



ការចាប់កូនត្រីពីហាប៉ា សម្រាប់លក់



ការរាប់កូនត្រីដាក់ចូលថង់ប្លាស្ទិក

## ២.១៥- ការគ្រប់គ្រងត្រីមេពូជ

ត្រីមេពូជជាបញ្ហាសំខាន់ក្នុងដំណើរការផលិតកូនត្រី។ វាមានឥទ្ធិពលយ៉ាងខ្លាំងទៅលើផលិតកម្មកូនត្រីទាំងបរិមាណ និងគុណភាព។ បើត្រីពូជមានគុណភាពល្អ គួបផ្សំនឹងការអនុវត្តបច្ចេកទេសបង្កាត់ និងថែបំប៉នកូនត្រីបានត្រឹមត្រូវតាមគោលការណ៍បច្ចេកទេស វានឹងផ្តល់ផលកូនត្រីពូជបានច្រើន ទាំងបរិមាណ និងគុណភាព ។ ដើម្បីសម្រេចគោលបំណងនេះ ត្រីមេពូជត្រូវយកចិត្តទុកដាក់គ្រប់គ្រង និងថែរក្សាឱ្យបានល្អត្រឹមត្រូវតាមបច្ចេកទេស។ ការធ្វើដូចនេះ ដើម្បី ៖

- ផលិតកូនត្រីពូជឱ្យមានគុណភាពល្អ
- កូនត្រីមានការលូតលាស់ឆាប់រហ័ស
- ផលិតត្រីពូជជំនាន់ក្រោយមានគុណភាពល្អ
- ជៀសវាងការផលិតកូនត្រីពូជអន់គុណភាព ដែលធ្វើឱ្យប៉ះពាល់ដល់ការចិញ្ចឹមត្រីសាច់មិនបានធំធាត់ និងកូនត្រីមានអត្រារស់តិច
- មានត្រីពូជមានសុខភាពល្អ និងកម្លាំងមាំមួនក្នុងសកម្មភាពបង្កាត់ពូជ ។

ដើម្បីគ្រប់គ្រងត្រីមេពូជឱ្យបានល្អ ត្រូវយកចិត្តទុកដាក់ដូចខាងក្រោម ៖

- ប្រភព ឬទីកន្លែង ដែលត្រីមេពូជរស់នៅ
- គុណភាពត្រីមេពូជ
- ការជីកស្រះបង្កាត់ និងស្រះថែបំប៉ន
- ដង់ស៊ីតេដាក់បំប៉នត្រីមេពូជ បង្កាត់ត្រី និងបំប៉នកូនត្រី
- គុណភាពទឹកស្រះបង្កាត់ ស្រះបំប៉ន
- ការផ្តល់ចំណី (ប្រភេទ បរិមាណ -គុណភាពចំណី និងពេលវេលាផ្តល់ចំណី)
- វិធីនៃការជ្រើសរើសត្រីមេពូជដែលមានគុណភាពល្អ ។

ម្យ៉ាងវិញទៀត កសិករផលិតកូនត្រីពូជត្រូវយកចិត្តទុកដាក់ថែបំប៉នត្រីមេពូជ ឱ្យបានល្អតាមបច្ចេកទេសដូចខាងក្រោម ៖

- ត្រូវចេះជ្រើសរើសត្រីមេពូជល្អៗ តាមគំនិតបានបញ្ជាក់ក្នុងមេរៀនខាងលើ ២.៧

- រួចត្រូវជ្រើសរើសត្រីញី និងត្រីឈ្មោល មកដាក់បំប៉នក្នុងស្រះ ២ ដាច់ដោយឡែកពីគ្នា ( ស្រះមួយសម្រាប់ត្រីឈ្មោល និងស្រះមួយទៀតសម្រាប់ត្រីញី ) រហូតដល់វាពេញវ័យបន្តពូជ
- កូនត្រីពូជដែលផលិតបាន ជាទូទៅតែងតែមាន កូនត្រី និងត្រីធំខ្លះមានសុខភាពមិនល្អ ។ ដូចនេះ កសិករត្រូវចាប់វាចេញ កុំឱ្យវានៅក្នុងស្រះជាមួយកូនត្រីពូជដែលល្អ
- បើមានលទ្ធភាព ជារៀងរាល់ឆ្នាំកសិករគួរផ្លាស់ប្តូរត្រីមេពូជចាស់ៗចេញ ដោយជ្រើសរើសយកត្រីមេពូជថ្មីៗមានគុណភាពល្អ មកដាក់បង្កាត់
- កសិករអាចធ្វើការផ្លាស់ប្តូរត្រីមេពូជបាន ដោយទៅទាក់ទងស្ថានីយ៍ស្រាវជ្រាវ និងផលិតកូនត្រីពូជរបស់រដ្ឋ ឬក៏ផ្លាស់ប្តូរត្រីមេពូជរបស់ខ្លួន ជាមួយត្រីមេពូជពីកន្លែងផ្សេងទៀត។

## ២.១៦- ការវិភាគសេដ្ឋកិច្ច

តារាងខាងក្រោមនេះ ជាឧទាហរណ៍នៃការវិភាគសេដ្ឋកិច្ច ការផលិតកូនត្រីពូជទីឡាព្យ៉ាជាលក្ខណៈគ្រួសារ ក្នុងស្រះទំហំ ១០០ ម$^{២}$ ក្នុងករណីគ្រប់គ្រងការផលិតបានល្អរយៈពេល ៨ ខែ ទទួលបានលទ្ធផលដូចខាងក្រោម ។

| សកម្មភាព | ការផលិតកូនត្រីពូជតាមទំលាប់ | | | | ការផលិតកូនត្រីពូជត្រូវបានកែលំអ | | | |
|---|---|---|---|---|---|---|---|---|
| | ឯកត្តា | ចំនួន | តម្លៃរាយ (៛) | តម្លៃសរុប (៛) | ឯកត្តា | ចំនួន | តម្លៃរាយ (៛) | តម្លៃសរុប (៛) |
| **ការជីកស្រះ** | | | | | | | | |
| ស្រះថ្មី | ម៣ | ៨៧ | ៣ ០០០ | **២៦១ ០០០** | ម៣ | ៨៧ | ៣ ០០០ | **២៦១ ០០០** |
| **ការរៀបចំស្រះ** | | | | | | | | |
| ថ្លៃឈ្នួលបូមទឹកស្រះ | ម៉ោង | ៣ | ៥ ០០០ | ១៥ ០០០ | ម៉ោង | ៣ | ៥ ០០០ | ១៥ ០០០ |
| កំបោរ | គ.ក្រ | ១០ | ១ ២០០ | ១២ ០០០ | គ.ក្រ | ១០ | ១ ២០០ | ១២ ០០០ |
| ជីអ៊ុយរ៉េ | គ.ក្រ | ១,៥ | ១ ៦០០ | ២ ៤០០ | គ.ក្រ | ១,៥ | ១ ៦០០ | ២ ៤០០ |
| ជីដេអាប៉េ | គ.ក្រ | ០,៥ | ១ ៨០០ | ៩០០ | គ.ក្រ | ០,៥ | ១ ៨០០ | ៩០០ |
| ជីលាមកសត្វ | គ.ក្រ | ៤០ | ០ | ០ | គ.ក្រ | ៤០ | ០ | ០ |
| ជីរុក្ខជាតិបៃតង | គ.កុ្រ | ១០ | ០ | ០ | គ.ក្រ | ១០ | ០ | ០ |
| សរុប | | | | ៣០ ៣០០ | | | | ៣០ ៣០០ |
| **ការដាក់កូនត្រីចិញ្ចឹម** | | | | | | | | |
| ៣- ៤ ប្រភេទ | ក្បាល | ៦០០ | ៥០ | ៣០ ០០០ | ក្បាល | ១០០ | ៦០០ | ៦០ ០០០ |
| **ការផ្តល់ចំណីបន្ថែម** | | | | | | | | |
| កន្ទក់ | គ.ក្រ | ២០ | ៥៥០ | ១១ ០០០ | គ.ក្រ | ២០ | ៥៥០ | ១១ ០០០ |
| ចក | គ.ក្រ | ៥០ | | ០ | គ.ក្រ | ៥០ | | ០ |
| ជន្លេន | គ.ក្រ | ៥ | | ០ | គ.ក្រ | ៥ | | ០ |
| កាកសំណល់បន្លែ | គ.ក្រ | ១០ | | ០ | គ.ក្រ | ១០ | | ០ |
| សរុប | | | | ១១ ០០០ | | | | ១១ ០០០ |
| **ការគ្រប់គ្រងស្រះ** | | | | | | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ជីអ៊ុយរ៉េ | គ.ក្រ | ១,៥ | ១ ៦០០ | ២ ៤០០ | គ.ក្រ | ១,៥ | ១ ៦០០ | ២ ៤០០ |
| ជីដេអាប៉េ | គ.ក្រ | ០,៥ | ១ ៨០០ | ៩០០ | គ.ក្រ | ០,៥ | ១ ៨០០ | ៩០០ |
| ជីលាមកសត្វ | គ.ក្រ | ៤០ | ០ | ០ | គ.ក្រ | ៤០ | ០ | ០ |
| ជីរុក្ខជាតិបៃតង | គ.ក្រ | ១០ | ០ | ០ | គ.ក្រ | ១០ | ០ | ០ |
| សរុប | | | | ៣ ៣០០ | | | | ៣ ៣០០ |
| **ប្រាក់ចំណាយសរុប** | | | | ៧៤ ៦០០ | | | | ១០៤ ៦០០ |
| **ប្រាក់ចំណាយសរុបលើសំភារៈផលិតកូនត្រី** | | | | | | | | |
| អួនអូស | | | | ០ | សម្រាប់ | ១ | ៤០០០០០ | ៤០០ ០០០ |
| ហាប៉ា (៣ម. ២ម. ១ម) | | | | ០ | សម្រាប់ | ១ | ៣០ ០០០ | ៣០ ០០០ |
| ប្រាក់ចំណាយសរុបលើសំភារៈ | | | | ០ | | | | ៤៣០ ០០០ |
| ការចំណាយរំលោះក្នុង ១ឆ្នាំ | | | | ០ | | | | ១៤០ ០០០ |
| **ប្រាក់ចំណូលពីផលត្រីសាច់** | គ.ក្រ | ៣៦ | ៥ ០០០ | **១៨០ ០០០** | | | | |
| **ប្រាក់ចំណូលពីផលកូនត្រី** | | | | | ក្បាល | ១៤ ០០០ | ៥០ | **៧០០ ០០០** |
| ប្រាក់ចំណេញសរុប= ប្រាក់ចំណូលសរុប- ប្រាក់ចំណាយសរុប | | | | **១០៥ ៤០០** | | | | **៤៥៥ ៤០០** |
| **ការវិភាគសេដ្ឋកិច្ចបន្ទាប់បន្សំ ស្រះចិញ្ចឹមត្រីសាច់** | | | | | | | | |
| ប្រាក់ចំណាយបន្ទាប់បន្សំ (ថ្នង ហាប៉ា ចំណី) | | | | | សម្រាប់ | ១ | ៥០ ០០០ | ៥០ ០០០ |
| ប្រាក់ចំណូលបន្ទាប់បន្សំ (កូនត្រីទីឡាព្យ៉ា) | | | | | ក្បាល | ២ ០០០ | ៥០ | ១០០ ០០០ |
| ប្រាក់ចំណេញបន្ទាប់បន្សំ | | | | | | | | **៥០ ០០០** |
| % នៃការបង្វិលទុនបន្ទាប់បន្សំ = (ប្រាក់ចំណូល- ប្រាក់ចំណាយ)/ ប្រាក់ចំណាយបន្ទាប់បន្សំ | | | | | | | | ១០០ % |
| ប្រាក់ចំណេញសរុបរួម= (ប្រាក់ចំណូលសរុប- ប្រាក់ចំណាយសរុប) + ប្រាក់ចំណេញបន្ទាប់បន្សំ | | | | | | | | **១៥៥ ៤០០** |
| **ការវិភាគសេដ្ឋកិច្ចបន្ទាប់បន្សំ ស្រះផលិតកូនត្រីទីឡាព្យ៉ា** | | | | | | | | |
| ប្រាក់ចំណាយបន្ទាប់បន្សំ | | | | | | | | ០ |
| ប្រាក់ចំណូលបន្ទាប់បន្សំ (ពីការលក់ត្រីមេពូជទីឡាព្យ៉ា) | | | | | ក្បាល | ១០០ | ៦០០ | ៦០ ០០០ |
| ប្រាក់ចំណេញបន្ទាប់បន្សំ | | | | | | | | **៦០ ០០០** |
| % នៃការបង្វិលទុនបន្ទាប់បន្សំ = (ប្រាក់ចំណូល- ប្រាក់ចំណាយ)/ ប្រាក់ចំណាយបន្ទាប់បន្សំ | | | | | | | | ១០០ % |
| ប្រាក់ចំណេញសរុបរួម= (ប្រាក់ចំណូលសរុប- ប្រាក់ចំណាយសរុប) + ប្រាក់ចំណេញបន្ទាប់បន្សំ | | | | | | | | **៥១៥ ៤០០** |

## ៣- វិធីសាស្ត្រផ្សព្វផ្សាយ

### ៣.១- ការសិក្សាទីផ្សារ និងការធ្វើផែនការផលិតកម្មកូនត្រីពូជ

ផលិតកម្មកូនត្រីពូជ អាចដំណើរការទៅបានជោគជ័យមិនអាស្រ័យទៅលើបច្ចេកទេសតែមួយមុខប៉ុណ្ណោះទេ ចាំបាច់តម្រូវឱ្យមានការសិក្សាទីផ្សារផងដែរ ។ ការសិក្សានេះ គឺដើម្បីកំណត់នូវបរិមាណកូនត្រីពូជដែលទីផ្សារតម្រូវការក្នុងឆ្នាំនីមួយៗ ។ បើយើងបានដឹងច្បាស់ពីតម្រូវការបរិមាណកូនត្រីពូជ យើងអាចកំណត់បានបរិមាណត្រីមេពូជ និងក្រឡាផ្ទៃ

ស្រះ ដែលត្រូវដំណើរការ ដើម្បីផលិតកូនត្រីពូជបានតាមចំនួនតម្រូវការទីផ្សារនោះ ។ ខាងក្រោមនេះជាការគណនារកបរិមាណត្រីមេពូជ និងផ្ទៃស្រះសរុប ដើម្បីទទួលបានបរិមាណកូនត្រីពូជ ៧០.០០០ក្បាល ក្នុង ១ឆ្នាំ ។

| **ការសន្មត់ នៃផលិតកម្មកូនត្រីពូជ** | **ផ្ទៃស្រះតម្រូវការ** | **បរិមាណត្រីមេពូជតម្រូវការ** |
|---|---|---|
| -១.០០០ កូនត្រី (១៥ក្រាម)ក្នុង ១០០ម$^2$ រយៈពេល ២ សប្តាហ៍<br>- ដូចនេះ ៥០០កូនត្រី ក្នុង ១០០ម$^2$ ក្នុង ១ សប្តាហ៍<br>-និង ១៤.០០០កូនត្រី ក្នុង ១០០ម$^2$ ក្នុង ២៨ សប្តាហ៍ | -១៤.០០០ កូនត្រី ក្នុង ១០០ម$^2$ រយៈពេល ២៨សប្តាហ៍<br>-ដូចនេះ ៧០.០០០កូនត្រី ត្រូវការផ្ទៃស្រះ <u>៥០០ម២ សម្រាប់រយៈពេល ២៨សប្តាហ៍</u> | -ត្រីមេពូជ ១ក្បាលដាក់បង្កាត់ក្នុង១ម$^2$<br>-ដូចនេះស្រះ ៥០០ម២ត្រូវដាក់ត្រីមេពូជ ៥០០ក្បាល ក្នុងនោះដាក់<br>-ត្រីញី=៥០០ក្បាល ៦០%=៣០០ក្បាល<br>-ត្រីឈ្មោល= ៥០០ក្បាល x ៤០%= ២០០ក្បាល |
| - ត្រីមេពូជ ១ក្បាលដាក់បង្កាត់ ក្នុង ១ម$^2$<br>- ដូចនេះ ត្រីមេពូជ ១០០ក្បាល ក្នុង ១០០ម$^2$<br>- ត្រីមេ = ៦០% និងឈ្មោល= ៤០% | | |
| -រយៈពេលផលិតកូនត្រីពូជ = ៨ខែ ឬ ៣៤ សប្តាហ៍<br>- ក្រោយដាក់ត្រីមេពូជ ទីឡាព្យ៉ា ៦សប្តាហ៍ កសិករចាប់ផ្តើមប្រមូលផលកូនត្រី<br>- ដូចនេះ កសិករប្រមូលផលកូនត្រីក្នុងរយៈពេល ២៨សប្តាហ៍ | | |

ការប៉ាន់ប្រមាណគណនាខាងលើនេះ គ្រាន់តែជាជំនួយសម្រាប់អ្នកផ្សព្វផ្សាយ ឬកសិករផលិតកូនត្រីក្នុងការកំណត់រកអ្វី (ប្រភេទ និងបរិមាណ) ដែលជាតម្រូវការសម្រាប់ផលិតកូនត្រីពូជតាមសេចក្តីត្រូវការទីផ្សារ ។ ចំនួនពិតប្រាកដនៃកូនត្រីផលិតបានក្នុង ១០០ម$^2$ ក្នុង ១សប្តាហ៍ អាស្រ័យទៅនឹងកត្តាផ្សេងៗគ្នាជាច្រើន ដូចចំណុចមេរៀនបានរៀបរាប់ខាងលើ ។ ត្រីមេពូជជាកត្តាសំខាន់មួយ ដែលអ្នកផលិតត្រូវជ្រើសរើសឱ្យបានល្អ ដូចជាជ្រើសរើសត្រីមេពូជមានទំងន់ពី ១០០ ទៅ ១៥០ក្រាមក្នុង ១ក្បាល ។ ត្រីមេពូជដែលមិនទាន់ពេញវ័យល្អ (នៅតូច) មានសុខភាពមិនរឹងមាំ មិនអាចផលិតកូនត្រីបានចំនួនដូចការប៉ាន់ប្រមាណក្នុងតារាងខាងលើឡើយ ។ បរិមាណកូនត្រីផលិតបាន ១.០០០ក្បាលក្នុង ១០០ម$^2$ ក្នុង ២សប្តាហ៍ គ្រាន់តែជាការប៉ាន់ប្រមាណក្នុងការងារអនុវត្ត ដើម្បីជាមូលដ្ឋានយកមកគណនារកតម្រូវការកូនត្រីពូជសរុប ។

### ៣.២- ការផ្សព្វផ្សាយបច្ចេកទេស

### វិធីសាស្ត្រអនុវត្តន៍

តារាងខាងក្រោមនេះ ជាចំណុចសំខាន់ៗ នៃសកម្មភាពផ្សព្វផ្សាយ ។ ចំណុចសំខាន់នីមួយៗ នឹងធ្វើការបកស្រាយលំអិតដូចខាងក្រោម៖




**ការជ្រើសរើសទីកន្លែង**

ការជ្រើសរើសទីកន្លែង ដើម្បីអភិវឌ្ឍសកម្មភាពផលិតកូនត្រី ជាកត្តាសំខាន់ក្នុងការកំណត់នូវភាពជោគជ័យរបស់គម្រោង ហើយជាទូទៅអាចអនុវត្តចាប់ពីខែ តុលា ដល់ខែ ធ្នូ ។ ខាងក្រោមនេះ ជាលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីកន្លែង ដើម្បីអភិវឌ្ឍសកម្មភាពផលិតកូនត្រី (មានបង្ហាញលំអិតនៅមេរៀន ២.២) ។

- ខ្វះការផ្គត់ផ្គង់កូនត្រីពូជនៅក្នុងតំបន់
- មានកសិករចិញ្ចឹមត្រីជាច្រើនរកទិញកូនត្រីពូជ
- មានកសិករជាច្រើនគ្រួសារចាប់អារម្មណ៍ការចិញ្ចឹមត្រី
- មានស្រះចិញ្ចឹមត្រីច្រើននៅក្នុងតំបន់
- មានប្រភពធនធានចំណីធម្មជាតិ សម្រាប់ចិញ្ចឹមត្រី
- មានប្រភពទឹកដែលអាចផ្គត់ផ្គង់ទឹកសម្រាប់ចិញ្ចឹមត្រីបានរយៈពេល យ៉ាងហោចណាស់ ៦ ខែ
- គ្មានទឹកជំនន់លិចខ្លាំង នៅរដូវវស្សា
- មានកសិករដែលអាចមានលទ្ធភាព និងសមត្ថភាពក្លាយជាអ្នកផលិតកូនត្រី ។

**ការរៀបចំសិក្ខាសាលាកសិករ**

ការរៀបចំសិក្ខាសាលាកសិករ គឺដើម្បីធានាដល់ភាពជោគជ័យ នៃការចាប់ផ្តើមអនុវត្តសកម្មភាពផ្សព្វផ្សាយផលិតកម្មកូនត្រី ចាប់ពីខែ តុលា ឬខែ ធ្នូ នៅក្រោយពេលជ្រើសរើសទីកន្លែងរួច និងនៅមុនពេលរដូវភ្លៀងធ្លាក់មកដល់ ពីព្រោះនៅរដូវភ្លៀងកសិករចាប់ផ្តើមរកទិញកូនត្រីពូជចិញ្ចឹម។ សិក្ខាសាលានេះរៀបចំឡើង ដើម្បីប្រមូលព័ត៌មាន និងពិភាក្សាជាមួយកសិករអំពីលក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសទីកន្លែង និងកសិករ ដើម្បីផ្សព្វផ្សាយបច្ចេកទេសផលិតកូនត្រីពូជព្រមទាំងផ្តល់ព័ត៌មានទៅកសិករវិញអំពី យុទ្ធសាស្ត្រនៃការអភិវឌ្ឍន៍សកម្មភាពផលិតកូនត្រីពូជនៅក្នុងតំបន់។

**ការរៀបចំផែនការសកម្មភាព**

ផែនការសកម្មភាពផលិតកូនត្រីពូជ នឹងត្រូវបានរៀបចំសម្រេច នៅក្រោយពេលសិក្ខាសាលាកសិកររួច ដោយផ្អែកលើលទ្ធផលសិក្ខាសាលាដែលបានពិភាក្សាជាមួយកសិករ។ ផែនការសកម្មភាពនេះនឹងរៀបរាប់សកម្មភាពសំខាន់ៗ ជាលំដាប់លំដោយ តាំងពីសកម្មភាពចាប់ផ្តើមដំបូង រហូតដល់បញ្ចប់សកម្មភាពជាយុទ្ធសាស្ត្រ ដោយមានបញ្ជាក់ពីពេលវេលាដែលត្រូវអនុវត្តដូចខាងក្រោម ៖-

| **សកម្មភាព** | **មករា** | **កុម្ភៈ** | **មិនា** | **មេសា** | **ឧសភា** | **មិថុនា** | **កក្កដា** | **សីហា** | **កញ្ញា** | **តុលា** | **វិច្ឆិកា** | **ធ្នូ** |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ការជ្រើសរើសទីកន្លែង | | | | | | | | | | | | |
| ការរៀបចំសិក្ខាសាលាកសិករ | | | | | | | | | | | | |
| ការរៀបចំផែនការ | | | | | | | | | | | | |
| ការជ្រើសរើសកសិករ | | | | | | | | | | | | |
| រៀបចំធ្វើបង្ហាញសកម្មភាពផលិតកូនត្រី | | | | | | | | | | | | |
| ផ្តល់វគ្គបណ្តុះបណ្តាល | | | | | | | | | | | | |
| ផ្តល់សំភារៈខ្លះៗ សម្រាប់អនុវត្ត | | | | | | | | | | | | |
| តាមដានសកម្មភាព និងផ្សព្វផ្សាយ | | | | | | | | | | | | |
| វាយតម្លៃ និងធ្វើរបាយការណ៍ | | | | | | | | | | | | |
| រៀបចំសិក្ខាសាលាកសិករបញ្ចប់ | | | | | | | | | | | | |
| រៀបចំផែនការអនុវត្តបន្ត | | | | | | | | | | | | |
| ជ្រើសរើសកសិករផលិតកូនត្រីពូជ ថ្មីៗ | | | | | | | | | | | | |

**ការជ្រើសរើសកសិករ**

ការជ្រើសរើសកសិករ ត្រូវចាប់ផ្តើមអនុវត្តភ្លាម ក្រោយពេលរៀបចំផែនការសម្រេចហើយ ពីព្រោះដំណើរការផលិតកម្មកូនត្រីពូជ ត្រូវការពេលវេលាពី ៤-៥ខែ មុនពេលរដូវភ្លៀងមកដល់ បើមិនដូចនេះទេ កសិករផលិតមិនមានកូនត្រីធំៗ និងមិនមានបរិមាណគ្រប់គ្រាន់សម្រាប់លក់ឱ្យកសិករចិញ្ចឹមបានឡើយ។ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករ ត្រូវផ្អែកលើមេរៀនខាងលើនៅចំណុចទី ២.៣ និងយោងតាមព័ត៌មានប្រមូលបានពីសិក្ខាសាលាកសិករ។

**ការរៀបចំធ្វើបង្ហាញសកម្មភាពផលិតកូនត្រី**

ជាដំបូងត្រូវរៀបចំផែនការសម្រាប់ដំណើរការសកម្មភាព ដោយប្រើប្រាស់ស្រះកសិករដែលយើងបានជ្រើស

រើស ។ ដើម្បីដំណើរការសកម្មភាពនេះឱ្យមានប្រសិទ្ធិភាព អ្នកផ្សព្វផ្សាយត្រូវរើសយកកសិករពី ១-២គ្រួសារ នៅឆ្ងាយពីគ្នាក្នុងឃុំតែមួយ ដោយប្រើវិធីសាស្ត្រជ្រើសរើសកសិករ ដែលបានរៀបរាប់នៅចំណុច ២.៣ ។

**ការផ្តល់វគ្គបណ្តុះបណ្តាល**

ក្រោយពេលរៀបចំចងក្រងក្រុមកសិករធ្វើបង្ហាញ ត្រូវផ្តល់វគ្គបណ្តុះបណ្តាលបច្ចេកទេសផលិតកូនត្រីពូជ (ទីឡាព្យ៉ា) ដល់ក្រុមកសិករដែលបានជ្រើសរើស ដោយយកចំណុចសំខាន់ៗនៃមេរៀនបច្ចេកទេស ដែលបានរៀបរាប់ក្នុងសៀវភៅគោលការណ៍ណែនាំបច្ចេកទេសផលិតកូនត្រីនេះ មកបង្រៀន ។ វគ្គបណ្តុះបណ្តាលនេះត្រូវរៀបចំនៅកសិដ្ឋានផលិតកូនត្រី ដើម្បីងាយស្រួលរៀបចំសកម្មភាពអនុវត្តជាក់ស្តែង ។ ក្រៅពីនេះត្រូវរៀបចំផ្ទាំងរូបភាព និងសៀវភៅបច្ចេកទេសផលិតកូនត្រី សម្រាប់បង្ហាញ និងចែកឱ្យកសិករនៅពេលបង្រៀន ។ ម្យ៉ាងទៀត គួរអញ្ជើញរដ្ឋអំណាចក្នុងមូលដ្ឋានចូលរួមបើកវគ្គបណ្តុះបណ្តាល ដើម្បីបង្កើនការងារផ្សព្វផ្សាយបច្ចេកទេសផលិតកូនត្រី ឱ្យបានទូលំទូលាយទាំងក្នុងមូលដ្ឋាន និងនៅក្រៅមូលដ្ឋាន ។

**ការផ្តល់សំភារៈខ្លះៗសម្រាប់អនុវត្ត**

ការផ្តល់សំភារៈខ្លះៗ (សំភារៈដែលកសិករមិនមាននៅក្នុងតំបន់) សម្រាប់ការធ្វើបង្ហាញបច្ចេកទេសផលិតកូនត្រីដល់កសិករដែលបានជ្រើសរើស ជាវិធីមួយល្អ ដើម្បីលើកទឹកចិត្តដល់កសិករឱ្យខិតខំយកចិត្តទុកដាក់អនុវត្តបច្ចេកទេសផលិតកូនត្រីដែលគម្រោងផ្តល់ឱ្យ និងជួយផ្សព្វផ្សាយបទពិសោធន៍នេះដល់កសិករដទៃទៀតនៅក្នុងភូមិ និងនៅក្រៅភូមិ ។

ប្រភេទសំភារៈដែលគួរផ្តល់ឱ្យដោយគម្រោង ៖

- ត្រីមេពូជ
- ជីគីមី ដូចជា ជីអ៊ុយរ៉េ និងជីដេអាប៉េ
- អួនអូសកូនត្រី (បើមានលទ្ធភាព) ។

គួរកត់សំគាល់ថា ការផ្គត់ផ្គង់សំភារៈខ្លះៗដល់កសិករនេះ គួរផ្តល់ឱ្យនៅឆ្នាំទី ១ ប៉ុណ្ណោះ ដើម្បីឱ្យកសិករប្រឹងប្រែងធ្វើសកម្មភាពផលិតកូនត្រី ប្រឹងប្រែងរកចំណូល ដើម្បីមានទុនសម្រាប់បន្តអនុវត្តសកម្មភាពនៅឆ្នាំបន្តបន្ទាប់ទៀត ។

មធ្យោបាយ និងសំភារៈដែលកសិករត្រូវមាន ៖

- ស្រះផលិតកូនត្រី
- ហាប៉ា
- អួនអូសកូនត្រី (បើមានលទ្ធភាព)
- ម៉ាស៊ីនបូមទឹក និងប្រេងបូមទឹក
- ជីធម្មជាតិ ឬ ជីសរីរាង្គ (ជីលាមកសត្វ)
- ចំណីសម្រាប់បំប៉នត្រី (កន្ទក់ ម្សៅត្រី ចក ជន្លេន កណ្តៀរ ....)
- កម្លាំងពលកម្មមើលគ្រប់គ្រងស្រះត្រី

**ការចុះពិនិត្យសកម្មភាពផលិតកូនត្រីរបស់កសិករ និងផ្សព្វផ្សាយបច្ចេកទេស**

ការផលិតកូនត្រីជាសកម្មភាពមួយថ្មី សម្រាប់កសិករនៅតាមជនបទ ជាពិសេសកសិករដែលពុំមានបទពិសោធន៍ផលិតកូនត្រី។ ដូចនេះនៅឆ្នាំទី ១ ទាមទារឱ្យមានការធ្វើបង្ហាញ និងឱ្យគាត់បានអនុវត្តជាក់ស្តែង រហូតគាត់អាចអនុវត្តបានដោយខ្លួនឯង ។ ម្យ៉ាងទៀត ទោះបីជាកសិករបានទទួលការបណ្តុះបណ្តាលក៏ដោយ ក៏អ្នកផ្សព្វផ្សាយ ត្រូវឧស្សាហ៍ចុះត្រួត

ពិនិត្យសកម្មភាពផលិតកូនត្រីរបស់កសិករ ដើម្បីផ្តល់ដំបូន្មានបច្ចេកទេសបន្ថែមដល់គាត់ ធ្វើយ៉ាងណាឱ្យគាត់មាន សមត្ថភាពគ្រប់គ្រាន់ក្នុងការផលិតកូនត្រីឱ្យបានជោគជ័យ។ ខាងក្រោមនេះ ជាភារៈកិច្ចមួយចំនួនរបស់អ្នកផ្សព្វផ្សាយ ដែលគួរយកចិត្តទុកដាក់ដូចជា៖

- ចុះពិនិត្យ ដើម្បីវាយតម្លៃសមត្ថភាពកសិករ ក្នុងការអនុវត្តសៀវភៅផ្សព្វផ្សាយបច្ចេកទេសផលិតកូនត្រី ដោយស្វែងរកបញ្ហាបច្ចេកទេសឱ្យឃើញ និងផ្តល់វិធានការណ៍ដល់កសិករ ដើម្បីដោះស្រាយ។ អ្នកផ្សព្វផ្សាយគួរចុះជួយផ្តល់ដំបូន្មានដល់កសិករ ឱ្យបានយ៉ាងហោចណាស់មួយដង ក្នុងមួយសប្តាហ៍ ។
- គួរផ្តល់សៀវភៅសម្រាប់ឱ្យកសិករកត់ត្រា គ្រប់ព័ត៌មានដែលជាបញ្ហា និងការរីកចំរើន ដើម្បីងាយស្រួលក្នុងការវាយតម្លៃសមត្ថភាពការយល់ដឹងរបស់កសិករ
- ក្នុងពេលចុះពិនិត្យ អ្នកផ្សព្វផ្សាយគួរកត់ត្រាគ្រប់ព័តិមាន ទាំងបញ្ហាកសិករបានជួបប្រទះ និងសកម្មភាពរីកចម្រើនដើម្បីងាយស្រួលវាយតម្លៃសមត្ថភាព និងផ្តល់ដំបូន្មានកសិករនៅពេលក្រោយ
- ត្រួតពិនិត្យគុណភាពទឹក និងសកម្មភាពត្រីក្នុងស្រះ ដោយដាក់ចំណីឱ្យស៊ី
- អ្នកផ្សព្វផ្សាយត្រូវព្យាយាមរកឱ្យឃើញនូវបញ្ហាដែលកំពុងកើតមាន និងនឹងត្រូវកើតមាននៅពេលក្រោយព្រមទាំងមូលហេតុដែលនាំឱ្យកើតមានបញ្ហា
- គ្រប់បញ្ហាទាំងអស់ដែលរកឃើញ អ្នកផ្សព្វផ្សាយត្រូវព្យាយាមរកឱ្យឃើញនូវដំណោះស្រាយ ហើយពន្យល់កសិករឱ្យបានយល់ច្បាស់។
- អ្នកផ្សព្វផ្សាយត្រូវរៀបចំរបាយការណ៍សង្ខេបពីលទ្ធផលសកម្មភាពផលិតកូនត្រីរបស់កសិករ សម្រាប់ធ្វើបទបង្ហាញនៅពេលសិក្ខាសាលាកសិករ ដើម្បីឱ្យកសិករបានដឹង និងរៀនសូត្រពីគ្នាទៅវិញទៅមក នៅពេលចុងបញ្ចប់សកម្មភាពផលិតកូនត្រីដែលជាធម្មតាច្រើនធ្វើនៅក្នុងខែ វិច្ឆិកា ឬ ខែធ្នូ ។ ក្នុងករណីចាំបាច់ ដែលអ្នកផ្សព្វផ្សាយចង់ផ្តល់ព័តិមាន ឬដោះស្រាយបញ្ហាបច្ចេកទេសអ្វីមួយដល់កសិករ សិក្ខាសាលានេះអាចរៀបចំធ្វើនៅពេលណាមួយក៏បានក្នុងអំឡុងពេលកំពុងផលិតកូនត្រី ។

## ការវាយតម្លៃ និងធ្វើរបាយការណ៍

តាមរយៈការចុះពិនិត្យសកម្មភាពកសិករនេះ អ្នកផ្សព្វផ្សាយអាចធ្វើការវាយតម្លៃពីបញ្ហាបច្ចេកទេស និង បញ្ហាផ្សេងៗទៀតដែលកសិករបានជួបប្រទះ ការរីកចម្រើន ការយល់ដឹង និងផែនការកសិករដែលត្រូវអនុវត្តបន្ត ។ បន្ទាប់មកអ្នកផ្សព្វផ្សាយអាចរៀបចំផែនការសកម្មភាពជាមួយកសិករ ដែលត្រូវអនុវត្តបន្តនៅឆ្នាំក្រោយ ។

## ការរៀបចំសិក្ខាសាលាកសិករ

ការរៀបចំសិក្ខាសាលាបញ្ចប់ មួយរដូវនៃសកម្មភាពផលិតកូនត្រីពូជ ជាទូទៅច្រើនធ្វើនៅចុងឆ្នាំ ដើម្បីផ្តល់ឱកាសឱ្យកសិករបានរៀនសូត្របន្ថែម ដោយការពិភាក្សាផ្លាស់ប្តូរពិសោធន៍ ចំណេះដឹង ពីគ្នាទៅវិញ ទៅមក ដើម្បីបង្កើនសមត្ថភាព និងការយល់ដឹងក្នុងការផលិតកូនត្រីពូជនៅឆ្នាំបន្តបន្ទាប់ ឱ្យបានកាន់តែល្អប្រសើរ។ ក្នុងឱកាសសិក្ខាសាលានេះអ្នកផ្សព្វផ្សាយ ត្រូវធ្វើបទបង្ហាញពីលទ្ធផលដែលបានរកឃើញ (បញ្ហា ដំណោះស្រាយ និងការរីកចម្រើន ) និងវាយតម្លៃ នៅពេលបានចុះពិនិត្យសកម្មភាពកសិករ។ នៅចុងបញ្ចប់នៃសិក្ខាសាលា យើងនឹងទទួលបានដំណោះស្រាយបញ្ហា និងផែនការសកម្មភាពអនុវត្តបន្ត ដោយមានការចូលរួមពិភាក្សា និងឯកភាពពីកសិករ ។

**ការរៀបចំផែនការសកម្មភាពនៅឆ្នាំបន្ទាប់**

ក្រោយពីសិក្ខាសាលាកសិករចប់ អ្នកផ្សព្វផ្សាយនឹងទទួលបានគ្រប់ព័ត៌មានដែលទាក់ទងនឹងភាពរីកចំរើន ភាពខ្សោយ និងតម្រូវការកសិករ អនុសាសន៍ និងផែនការសកម្មភាពរបស់កសិករដែលត្រូវអនុវត្តបន្ត រួចបញ្ចូលទៅក្នុងផែនការសកម្មភាពរួមមួយសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់ ។

**ការជ្រើសរើសកសិករផលិតកូនត្រីពូជថ្មី (បន្ថែម)**

ពីមួយឆ្នាំទៅមួយឆ្នាំ ការផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រីត្រូវបានអភិវឌ្ឍកាន់តែខ្លាំងឡើងៗ ដោយអ្នកផ្សព្វផ្សាយ និងតាមរយៈការផ្សព្វផ្សាយពីកសិករទៅកសិករ នៅពេលនោះការចិញ្ចឹមត្រីនឹងជួបប្រទះបញ្ហាការខ្វះកូនត្រីពូជសម្រាប់ផ្គត់ផ្គង់ដល់កសិករចិញ្ចឹមត្រី។ ដើម្បីដោះស្រាយបញ្ហានេះ នៅចុងឆ្នាំទីមួយៗនៃការអនុវត្តរបស់គម្រោង ត្រូវយកចិត្តទុកដាក់បញ្ចូលសកម្មភាពជ្រើសរើសកសិករផលិតកូនត្រីពូជបន្ថែម (នៅក្នុងតំបន់ផ្សេងទៀត) ទៅក្នុងផែនការ សកម្មភាពនៅឆ្នាំបន្ទាប់ ដើម្បីធានាដល់ការផ្គត់ផ្គង់កូនត្រីពូជឱ្យបានគ្រប់គ្រាន់ ទៅកសិករចិញ្ចឹមត្រីទាំងនៅក្នុងតំបន់ និងនៅ ក្រៅតំបន់គោលដៅរបស់គម្រោង ។ លក្ខណៈវិនិច្ឆ័យនៃការជ្រើសរើសកសិករផលិតកូនត្រីពូជបន្ថែម នៅតំបន់ថ្មី សូមមើល នៅមេរៀនចំណុច ២.៣ ។

## ៣.៣- ការចំណាយសម្រាប់ការធ្វើបង្ហាញ

វិធីសាស្ត្រផ្សព្វផ្សាយដែលបានលើកយកមកបង្ហាញ មានកម្មវិធីទូលំទូលាយ ហើយដែលទាក់ទងគ្នារវាងអ្នកផ្សព្វផ្សាយ និងកសិករ ព្រមទាំងពេលវេលាសម្រាប់ធ្វើការផ្សព្វផ្សាយបង្ហាញនូវបច្ចេកទេសថ្មីៗ ។ ចំពោះគំរូសៀវភៅផ្សព្វផ្សាយបច្ចេកទេសនេះ ការចំណាយសម្រាប់ការអនុវត្តធ្វើបង្ហាញ មានសង្ខេបដូចក្នុងតារាងខាងក្រោម៖

| | សកម្មភាព | ចំនួន-តម្លៃ |
|---|---|---|
| ក | ក្រុមកសិករ | ១០ នាក់ |
| ខ | ទុនចូលរួមពីកសិករគំរូ | កម្លាំងពលកម្ម ស្រះចិញ្ចឹមត្រី ចំណីត្រី ជីធម្មជាតិ |
| គ | ទុនសម្រាប់ទីតាំងធ្វើបង្ហាញ | $ ១១៤ |
| ឃ | ឯកសារសម្រាប់ការបណ្តុះបណ្តាលក្រុមកសិករ | $ ២០ |
| ង | ការបណ្តុះបណ្តាលក្រុមកសិករ- អាហារសំរ៉ន់ | $ ៥០ |
| ច | ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រី- អាហារសំរ៉ន់ | $ ៥០ |
| ឆ | ទិវាផ្សព្វផ្សាយការចិញ្ចឹមត្រី- សំភារៈ | $ ២០ |
| ជ | មន្ត្រីកសិកម្មស្រុក- ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ | $ ៤២ |
| ឈ | មន្ត្រីកសិកម្មស្រុក- ប្រាក់ឧបត្ថម្ភថ្លៃធ្វើដំណើរ | $ ២៤ |
| ញ | ការចុះត្រួតពិនិត្យតាមដាននៅមូលដ្ឋានដោយអ្នកឯកទេសជំនាញ | $ ២០ |
| | **សរុប** | **$ ៣៤០** |

**សេចក្តីបញ្ជាក់ ដោយសន្ទត់**

ក- មានក្រុមកសិករ ១០នាក់ (មកពីបណ្តាឃុំផ្សេងៗគ្នា ក្នុង១ឃុំជ្រើសរើសយកកសិករ ១ម្នាក់) និងកសិករគំរូ ដែលមានទីកន្លែងធ្វើបង្ហាញចំនួន ២កន្លែង ស្ថិតនៅក្នុងឃុំផ្សេងគ្នា ។

ខ- ទុនចូលរួមពីកសិករ (សម្រាប់ ១កន្លែង) មានស្រះទំហំ ២០០ម² ចំនួន ២ ឧបករណ៍សម្រាប់ផលិតកូនត្រី (ដូចជា ថ្នងដួសកូនត្រី អួនចាប់ត្រីមេពូជ ឬចាប់កូនត្រី ម៉ាស៊ីនបូមទឹក) កម្លាំងពលកម្ម ចំណីត្រី (កន្ទក់ ចុងអង្ករ ចកបាយទា កណ្តៀវ ជន្លេន ....) និងជីធម្មជាតិ (លាមកគោ ក្របី ជ្រូក មាន់ ទា) ។

គ- ទុនសម្រាប់ធ្វើបង្ហាញការផលិតកូនត្រីក្នុងស្រះ១ កន្លែង ដោយមានរួមបញ្ចូល-ការរៀបចំស្រះ២ ទំហំ ៤០០ម២=4៣០

- ដាក់ត្រីមេពូជបង្កាត់ ១០០ក្បាល/ម² x ៦០០៛/ក្បាល = **<u>$១៥</u>** - ចំណីត្រី =4៥ -ជីគីមី = **<u>$២</u>**

- ការដឹកជញ្ជូន = **<u>$៥</u>** -សរុបទាំងអស់ = **<u>$៥៧</u>** ។ ដូចនេះ ការធ្វើបង្ហាញ ២កន្លែង អស់ប្រាក់ **<u>$១១៤</u>** ។

ឃ- ឯកសារបណ្តុះបណ្តាលបច្ចេកទេស រួមមាន សំភារៈសម្រាប់បង្រៀន - មេរៀន - ការបញ្ចាំងស្លាយ -និងផ្ទាំងរូបភាព ធំៗ ដែលជាដំណើរការវិធីសាស្ត្របង្រៀន ។

ង- ការបណ្តុះបណ្តាលក្រុមកសិករមាន ២វគ្គ មួយវគ្គមានរយៈពេល ២ថ្ងៃ

ច- ទិវាផ្សព្វផ្សាយការផលិតកូនត្រីមានកន្លះថ្ងៃ ក្នុង១វគ្គ និងត្រូវមានការចូលរួមពីកសិករនៅក្បែរៗភូមិ ប្រហែលពី ២០-៣០នាក់ ។

ឆ- សំភារៈសម្រាប់ទិវាផ្សព្វផ្សាយការផលិតកូនត្រី រួមមាន ឧឃោសនស័ព្ទ (មេក្រូ) ផ្ទាំងក្រដាសផ្លាស្ទិក និងផ្ទាំងបដា រូបភាពផ្សេងៗ

ជ- សម្រាប់មន្ត្រីកសិកម្មស្រុក ថវិកាឧបត្ថម្ភរួមមាន ៤ថ្ងៃ សម្រាប់ការជ្រើសរើសទីកន្លែងធ្វើបង្ហាញ ការចាប់ផ្តើម ការត្រួតពិនិត្យតាមដាន ។ ចំពោះការបណ្តុះបណ្តាលសម្រាប់ ២វគ្គ ផ្តល់ឱ្យ ៦ថ្ងៃ និង ទិវាផ្សព្វផ្សាយការផលិតកូនត្រី ទីឡាញ៉ាផ្តល់ឱ្យ ២ថ្ងៃ -សរុប **<u>១២ថ្ងៃ។</u>**

ឈ- ប្រាក់ឧបត្ថម្ភសម្រាប់ម៉ូតូ ២ដុល្លា សម្រាប់ ១ថ្ងៃ ទាំងអស់ ១២ថ្ងៃ

ញ- មន្ទីរកសិកម្មខេត្ត- អ្នកឯកទេសផ្តល់ជំនួញបច្ចេកទេស និងត្រួតពិនិត្យ —តាមដានការបណ្តុះបណ្តាល បអប ដែលធ្វើបង្ហាញ ។

ចំនួនថ្ងៃនៃសកម្មភាពទាំងនេះជាការប៉ាន់ប្រមាណសម្រាប់អនុវត្តបទដ្ឋានបច្ចេកវិទ្យានេះ នៅក្នុងស្រុកមួយ ដែលមានកសិកររស់នៅក្នុងឃុំផ្សេងពីគ្នា បានចូលរួមសកម្មភាពផលិតកូនត្រីក្នុងគម្រោងពី ៥ទៅ១០គ្រួសារ ។ ដើម្បីបំរើសេវាកម្មផ្សព្វផ្សាយបច្ចេកទេសចិញ្ចឹមត្រី និងទីផ្សារលក់កូនត្រីពូជបានល្អក្នុង១ឃុំ គប្បីជ្រើសរើសយកតែ ១គ្រួសារចូលរួម ក្នុងការផ្សព្វផ្សាយធ្វើបង្ហាញបច្ចេកទេសផលិតកូនត្រីពូជ ។

**ធនធានសំភារៈ**

ការិយាល័យវារីវប្បកម្ម នៃរដ្ឋបាលជលផល ដែលកំពុងសហប្រតិបត្តិការជាមួយបណ្តាអង្គការនានា និងជាមួយបណ្តាស្ថានីយស្រាវជ្រាវ ផលិតកូនត្រីពូជ ជាមជ្ឈមណ្ឌលផ្សព្វផ្សាយបច្ចេកទេសផលិតកូនត្រី និងផលិតឯកសារផ្សព្វផ្សាយ ។

### ៣.៤- ការចូលរួមរបស់ស្ត្រី ក្នុងសកម្មភាពវារីវប្បកម្ម

ស្ត្រីជាធនធានមនុស្សមួយយ៉ាងសំខាន់ ក្នុងការចូលរួមផ្សព្វផ្សាយសកម្មភាពវារីវប្បកម្ម ទាំងការចិញ្ចឹមត្រី និងផលិតកូនត្រីពូជ ព្រមទាំងអនុវត្តបច្ចេកទេសផលិតកូនត្រីក្នុងបទដ្ឋានបច្ចេកវិទ្យានេះ។ ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពនេះ គឺជាការចូលរួមចំណែកក្នុងការជំរុញសកម្មភាពអភិវឌ្ឍន៍វារីវប្បកម្មឱ្យទទួលបានជោគជ័យ។ ជាទូទៅ ស្ត្រីជាអ្នកជួយការងារវារីវប្បកម្មច្រើនក្នុងការគ្រប់គ្រងសកម្មភាពចិញ្ចឹមត្រី និងផលិតកូនត្រីប្រចាំថ្ងៃ។ បទដ្ឋានអនុវត្តបច្ចេកវិទ្យានេះនឹងផ្តល់ដល់ស្ត្រី នូវការរកប្រាក់ចំណូលក្នុងគ្រួសារតាមរយៈការចិញ្ចឹមត្រី និងផលិតកូនត្រីពូជ ដើម្បីលើកស្ទួយជីវភាពរស់នៅ ក្នុងការបង្កើនសារធាតុប្រូតេអ៊ីនក្នុងម្ហូបអាហារ និងផ្គត់ផ្គង់កូនចៅទៅសាលារៀន ព្រមទាំងសម្រាប់ការចំណាយផ្សេងៗទៀត ។

## ៤- សេចក្តីបន្ថែម

### ៤.១- បញ្ហាអាចកើតមានក្នុងពេលដំណើរការផលិតកម្មកូនត្រី និង វិធានការដោះស្រាយ

ភាពជោគជ័យនៃការផលិតកូនត្រីពូជ គឺសំដៅទៅលើការផលិតឱ្យបានច្រើនទាំងបរិមាណ និងមានគុណភាពល្អ។ ការងារនេះអាស្រ័យទៅលើការអនុវត្តបច្ចេកទេសផលិតកូនត្រីពូជ។ ក្នុងអំឡុងពេលផលិតកូនត្រី ជួនកាលកសិករបានជួបប្រទះនឹងបញ្ហាបច្ចេកទេសមួយចំនួន ដែលធ្វើឱ្យត្រីឈឺ និងងាប់ ។ ដូចនេះ តើយើងត្រូវដោះស្រាយបញ្ហានេះយ៉ាង ដូចម្តេច ? ខាងក្រោមនេះ ជាបញ្ហាដែលធ្វើឱ្យត្រីឈឺ និងងាប់ និងដំណោះស្រាយមួយចំនួនដោយផ្អែកលើបទពិសោធន៍ ការងារជាមួយកសិករនៅតាមមូលដ្ឋាន។

| បញ្ហា | ដំណោះស្រាយបញ្ហា |
|---|---|
| **១- ត្រីមេពូជងាប់ក្រោយពេលដឹកជញ្ជូន** អាចបណ្តាលមកពី ៖<br>- មានសុខភាពខ្សោយ<br><br>- មិនបង្អត់ចំណីត្រីមេពូជ ១ថ្ងៃ មុនពេលដឹកជញ្ជូន<br>- ដាក់ត្រីមេពូជច្រើនក្បាល ក្នុង ១ថង់<br><br>- ទឹកដាក់ក្នុងថង់មានគុណភាពមិនល្អ<br><br>- ដឹកជញ្ជូនត្រីប្រើរយៈពេលយូរ នៅពេលថ្ងៃកំពុងក្តៅ<br>- ខ្យល់អុកស៊ីសែនក្នុងថង់កូនត្រី មិនគ្រប់គ្រាន់ | **១- ត្រីមេពូជងាប់ក្រោយពេលដឹកជញ្ជូន**<br>- ជ្រើសរើសត្រីមេពូជមានសុខភាពល្អ មានសកម្មភាពរហ័សរហួន ដងខ្លួនមានពណ៌ភ្លឺថ្លា គ្មានដំបៅ របួស និងធំធាត់ (មេរៀន២.៧)<br>- កុំផ្តល់ចំណីឱ្យត្រីស៊ី ១ថ្ងៃ មុនពេលដឹកជញ្ជូន<br>- ចំពោះថង់ទំហំ ៦០ស.ម x ៨០ស.ម អាចដាក់ត្រីបានពី ២- ៥ ក្បាល អាស្រ័យទៅនឹងទំហំត្រី និងចំងាយផ្លូវដឹកជញ្ជូន<br>- អ្នកលក់ត្រីត្រូវប្រើទឹកស្រះដែលមានគុណភាពល្អ ដាក់ក្នុងថង់ត្រីសម្រាប់ដឹកជញ្ជូន<br>- កសិករគួរដឹកជញ្ជូនត្រីនៅពេលថ្ងៃ មេឃត្រជាក់<br>- អ្នកលក់ត្រីត្រូវបញ្ចូលខ្យល់អុកស៊ីសែនក្នុងថង់ឱ្យពេញណែនល្អ និងចងឱ្យជាប់។ |
| **២- ត្រីមេពូជ ឬកូនត្រីងាប់ក្រោយពេលដាក់ចិញ្ចឹម**<br>អាចបណ្តាលមកពី៖<br>- ទឹកក្នុងស្រះត្រីមានគុណភាពមិនល្អ ឬមានជាតិពុល<br><br>- ទឹកស្រះនៅមិនទាន់សាបជាតិកំបោរ ឬមានក្លិនស្អុយ | **២- ត្រីមេពូជ ឬកូនត្រីងាប់ក្រោយពេលដាក់ចិញ្ចឹម**<br><br>- ទឹកស្រះត្រីត្រូវរៀបចំឱ្យមានគុណភាពល្អ ពណ៌បៃតង គ្មានជាតិពុល<br>- អាចដាក់ត្រីក្នុងស្រះបាន ក្រោយពេលទឹកស្រះបានបន្សាបជាតិកំបោរអស់ |

| | |
|---|---|
| - លែងត្រីចូលស្រះរហ័សពេក<br><br><br>- លែងត្រីនៅពេលថ្ងៃកំពុងក្តៅខ្លាំង | - ត្រូវត្រាំថង់កូនត្រី ឬត្រីមេពូជ ក្នុងទឹកស្រះ ឱ្យបាន ៥ នាទី រួចស្រាយមាត់ថង់បាចទឹកស្រះបញ្ចូល  បន្ទាប់មកផ្អៀងមាត់ថង់ លែងត្រីចូលក្នុងស្រះដោយសន្សឹមៗ<br>- គួរលែងត្រីនៅពេលមេឃត្រជាក់ ឬមុនលែងត្រីចូលស្រះ ត្រូវយកដៃកូរទឹកស្រះ  ដើម្បីឱ្យសីតុណ្ហភាពទឹកស្រះខាងលើត្រជាក់ |
| **៣-  កូនត្រីបាត់បង់ក្នុងពេលដំណើរការផលិតកម្មកូនត្រី** អាចបណ្តាលមកពី ៖<br>- នៅមានត្រីកាចក្នុងស្រះបង្កាត់ពូជ  និងស្រះបំប៉នកូនត្រី | **៣-  កូនត្រីបាត់បង់ក្នុងពេលដំណើរការផលិតកម្មកូនត្រី**<br><br>- បើមានលទ្ធភាព  ដាក់របាំងសំណាញ់ព័ទ្ធជុំវិញស្រះ ដើម្បីកុំឱ្យត្រីស្រែលោតចូលស្រះ ក្រោយពេលរៀបចំស្រះហើយ<br>- ព្យាយាមចាប់ត្រីកាចចេញពីស្រះ ដោយប្រើវិធីកុំធ្វើឱ្យប៉ះពាល់ដល់កូនត្រីក្នុងស្រះ<br>- ក្នុងករណីមានសត្វល្អិតច្រើននៅក្នុងស្រះបំប៉នកូនត្រី  យើងអាចកាត់បន្ថយបរិមាណសត្វល្អិតបានដោយការអូសអួន មុនពេលដាក់កូនត្រី<br>- បើដាក់បំប៉នកូនត្រីម្សៅ  ស្រះបំប៉នកូនត្រីមិនត្រូវប្រើជីលាមកសត្វទេ ព្រោះវានាំឱ្យកើតសត្វល្អិត និងមមូងច្រើនក្នុងស្រះ (មានមេរៀនបញ្ជាក់នៅ ២.១១) |
| **៤-  កូនត្រីពូជមិនធំធាត់**  អាចបណ្តាលមកពី ៖<br>- ទឹកស្រះមានគុណភាពមិនល្អ  ខ្វះចំណីធម្មជាតិ ឬ ប្លង់តុង<br><br>- ដាក់កូនត្រីបំប៉នច្រើនពេក<br><br><br>- កូនត្រីខ្លះអាចមានជំងឺ | **៤-  កូនត្រីពូជមិនធំធាត់**<br>- ត្រូវឧស្សាហ៍ត្រួតពិនិត្យគុណភាពទឹកស្រះជាប្រចាំ ដោយកែលំអឱ្យមានពណ៌បៃតង សម្បូរចំណីធម្មជាតិ<br>- ត្រូវបន្ថយបរិមាណកូនត្រីដាក់ចិញ្ចឹម ពិសេសនៅពេលកូនត្រីមានទំហំធំ។  បើកូនត្រីមានទំហំ ៣-៥ ស.ម ចំនួនកូនត្រីដាក់ចិញ្ចឹមគួរដាក់ ពី ៣- ៤ ក្បាលក្នុង ម២ ស្រះ<br>- ត្រូវឧស្សាហ៍សង្កេតមើលស្រះបំប៉នកូនត្រី រៀងរាល់ថ្ងៃ  បើមានកូនត្រីងាប់  ឬ ឈឺ ត្រូវស្រង់វាចេញជាបន្ទាន់ ។ |
| **៥-មានកូនត្រី  ឬត្រីមេពូជងាប់ក្នុងពេលដំណើរការផលិតកម្ម** អាចបណ្តាលមកពី ៖<br>- ទឹកស្រះមានជាតិពុល ដែលអាចនាំមកពីកន្លែងផ្សេង តាមរយៈទឹកភ្លៀង<br><br>- នៅលើផ្ទៃទឹកស្រះមានរុក្ខជាតិទឹកដុះគ្របពេញស្រះ<br><br>- មានចកនៅសល់ពីត្រីស៊ីច្រើនពេក  នៅលើផ្ទៃទឹកស្រះ<br>- ទឹកស្រះរាក់ ល្អក់ ហើយក្តៅ | **៥-មានកូនត្រី  ឬត្រីមេពូជងាប់ក្នុងពេលដំណើរការផលិតកម្ម**<br><br>- កន្លែងចិញ្ចឹមត្រី និងផលិតកូនត្រីពូជ គួរស្ថិតនៅឱ្យឆ្ងាយពីកន្លែងដែលមានប្រើប្រាស់ថ្នាំពុល ឬជាតិគីមីផ្សេងៗ (សូមមើលរូបភាពនៅមេរៀន ២.៥.១)<br>- មិនត្រូវឱ្យមានរុក្ខជាតិទឹកដុះគ្របពេញផ្ទៃទឹកស្រះ បើមានត្រូវស្រង់ ឬដកវាចេញ<br>- ត្រូវដាក់ចកក្នុងស៊ុមចំណីបណ្តែតទឹក<br>- ត្រូវរក្សាបរិមាណទឹកឱ្យបានច្រើននៅក្នុងស្រះត្រី និងមានពណ៌ |

| | |
|---|---|
| - មានភក់បាតស្រះច្រើនពេក | បែតងជាប់ជានិច្ច ។<br>- នៅពេលរៀបចំស្រះ កសិករត្រូវបារភក់បាតស្រះចេញ ដោយទុកឱ្យមានជម្រៅពី ១០-២០ ស.ម ។ |
| **៦- ផលិតផលកូនត្រីមានបរិមាណតិច ពីស្រះបង្កាត់** អាចបណ្ដាលមកពី ៖<br>- គុណភាពត្រីមេពូជមិនល្អ<br><br>- មានត្រីកាចនៅក្នុងស្រះបង្កាត់<br>- លក្ខខណ្ឌស្រះបង្កាត់មិនល្អ | **៦- ផលិតផលកូនត្រីមានបរិមាណតិច ពីស្រះបង្កាត់**<br><br>- ជ្រើសរើសតែត្រីមេពូជល្អដាក់បង្កាត់ក្នុងស្រះ (មានមេរៀនបញ្ជាក់នៅចំណុច ២.៧ និង ២.១៥)<br>- ត្រីមេពូជត្រូវធ្វើការផ្លាស់ប្ដូរ រៀងរាល់ ១- ២ ឆ្នាំ ម្ដង<br>- មើលមេរៀន ៤.១ ចំណុចទី៣<br>- បើមានលទ្ធភាព គួរធ្វើការផ្លាស់ប្ដូរទឹកក្នុងស្រះបង្កាត់ដោយបង្ហូរទឹកចាស់ចេញខ្លះ ដាក់ទឹកថ្មីចូល ដែលគ្មានជាតិពុល<br>- ស្រះបង្កាត់ត្រូវរៀបចំសំអាត រៀងរាល់ឆ្នាំ ដើម្បីកែលំអគុណភាពទឹក រៀបចំជើងទេរស្រះ បារភក់បាតស្រះ និងចាប់ត្រីកាចចេញ ។ |

## ៤-២. ការប្រមូលទិន្នន័យផលិតកម្មកូនត្រីពូជ

**តារាងប្រមូលទិន្នន័យប្រចាំថ្ងៃ សកម្មភាពបង្កាត់ ឬ បំប៉នកូនត្រី**

ផលិតកម្មកូនត្រីទីឡាព្យ៉ាឆ្នាំ ..................... ខែ ................. ស្រះលេខ .................. ទំហំស្រះ ............... ម$^2$

| ថ្ងៃ | បរិមាណជីដាក់ស្រះ (គ.ក្រ) | | | | | បរិមាណចំណី (គ.ក្រ) | | | | ការសង្កេត |
|---|---|---|---|---|---|---|---|---|---|---|
| ប្រមូល | លាមកគោ | ល.ជ្រូក | ជីបៃតង | អ៊ុយរ៉េ | ដេអាប៉េ | ចក | កាកបន្លែ | កន្ទក់ | ផ្សេងៗ | បញ្ហាកើតមាន |
| 1 | | | | | | | | | | |
| 2 | | | | | | | | | | |
| 3 | | | | | | | | | | |
| 4 | | | | | | | | | | |
| 5 | | | | | | | | | | |
| 6 | | | | | | | | | | |
| 7 | | | | | | | | | | |
| 8 | | | | | | | | | | |
| 9 | | | | | | | | | | |
| 10 | | | | | | | | | | |
| 11 | | | | | | | | | | |
| 12 | | | | | | | | | | |
| 13 | | | | | | | | | | |
| 14 | | | | | | | | | | |
| 15 | | | | | | | | | | |
| 16 | | | | | | | | | | |
| 17 | | | | | | | | | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 18 | | | | | | | | | | |
| 19 | | | | | | | | | | |
| 20 | | | | | | | | | | |
| 21 | | | | | | | | | | |
| 22 | | | | | | | | | | |
| 23 | | | | | | | | | | |
| 24 | | | | | | | | | | |
| 25 | | | | | | | | | | |
| 26 | | | | | | | | | | |
| 27 | | | | | | | | | | |
| 28 | | | | | | | | | | |
| 29 | | | | | | | | | | |
| 30 | | | | | | | | | | |
| 31 | | | | | | | | | | |
| សរុប | | | | | | | | | | |

**តារាងប្រមូលទិន្នន័យប្រចាំខែ សកម្មភាពបន្ទាត់**

ផលិតកម្មកូនត្រីទីឡាព្យ៉ាឆ្នាំ ..................... ខែ ..................

| ស្រែះ | ចំនួនត្រីមេពូជ | | បរិមាណជីដាក់ស្រែះ (គ.ក្រ) | | | | | បរិមាណចំណី (គ.ក្រ) | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| លេខ | ឈ្មោល- ញី | | លាមកគោ | ល.ជ្រូក | ជីបៃតង | អ៊ុយរ៉េ | ដេអាប៉េ | ចក | កាកបន្លែ | កន្ទក់ | ផ្សេងៗ |
| ផ្ទៃស្រែះ | ឈ្មោល | ញី | | | | | | | | | |
| 1 | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័ត៌មានអំពី ៖ បញ្ហាកើតមានឡើង ការលំបាក ការរីកចំរើន អនុសាសន៍ សំណូមពរ | | | | | | | | |
| ........ | | | | | | | | | | | |
| ម² | | | | | | | | | | | |
| 2 | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័ត៌មានអំពី ៖ បញ្ហាកើតមានឡើង ការលំបាក ការរីកចំរើន អនុសាសន៍ សំណូមពរ | | | | | | | | |
| ......... | | | | | | | | | | | |
| ម² | | | | | | | | | | | |
| 3 | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័ត៌មានអំពី ៖ បញ្ហាកើតមានឡើង ការលំបាក ការរីកចំរើន អនុសាសន៍ សំណូមពរ | | | | | | | | |
| ......... | | | | | | | | | | | |
| ម² | | | | | | | | | | | |
| 3 | | | | | | | | | | | |

**កំណត់សំគាល់**

អ៊ុយរ៉េ ........................៛/ គ.ក្រ កន្ទក់ .................................៛/ គ.ក្រ

ដេអាប៉េ ......................៛/ ត.ក្រ      កាកសំណល់បន្លែ ........................៛/ ត.ក្រ

លាមកជ្រូក ...................៛/ ត.ក្រ      ផ្សេងៗ ................................៛/ ត.ក្រ

លាមកគោ .................. ៛/ ត.ក្រ      អត្រាប្តូរប្រាក់ ....................... ៛/ $

**តារាងប្រមូលទិន្នន័យប្រចាំខែ  សកម្មភាពចិញ្ចឹមត្រី**

ផលិតកម្មកូនត្រីទីឡាព្យ៉ាឆ្នាំ .................... ខែ .................

| ស្រះ | ចំនួនកូនត្រី | | បរិមាណជីដាក់ស្រះ (ត.ក្រ) | | | | | បរិមាណចំណី (ត.ក្រ) | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| លេខ | ចាប់ប្រមាណ | | លាមកគោ | ល.ជ្រូក | ជីបៃតង | អ៊ុយរ៉េ | ដេអាប៉េ | ចក | កាកបន្លែ | កន្ទក់ | ផ្សេងៗ |
| ផ្ទៃស្រះ | ចំនួន | ស.ម | | | | | | | | | |
| 1 | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័ត៌មានអំពី ៖ បញ្ហាកើតមានឡើង  ការលំបាក ការរីកចំរើន  អនុសាសន៍  សំណូមពរ | | | | | | | | |
| ........ | | | | | | | | | | | |
| ម² | | | | | | | | | | | |
| 2 | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័ត៌មានអំពី ៖ បញ្ហាកើតមានឡើង  ការលំបាក ការរីកចំរើន  អនុសាសន៍  សំណូមពរ | | | | | | | | |
| ......... | | | | | | | | | | | |
| ម² | | | | | | | | | | | |
| 3 | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័ត៌មានអំពី ៖ បញ្ហាកើតមានឡើង  ការលំបាក ការរីកចំរើន  អនុសាសន៍  សំណូមពរ | | | | | | | | |
| ......... | | | | | | | | | | | |
| ម² | | | | | | | | | | | |
| 3 | | | | | | | | | | | |

**កំណត់សំគាល់**

អ៊ុយរ៉េ ......................៛/ ត.ក្រ      កន្ទក់ ..................................៛/ ត.ក្រ

ដេអាប៉េ ......................៛/ ត.ក្រ      កាកសំណល់បន្លែ ..................៛/ ត.ក្រ

លាមកជ្រូក ...................៛/ ត.ក្រ      ផ្សេងៗ ................................៛/ ត.ក្រ

លាមកគោ .................. ៛/ ត.ក្រ      អត្រាប្តូរប្រាក់ ....................... ៛/ $

**តារាងប្រមូលទិន្នន័យប្រចាំខែ សកម្មភាពបង្កាត់ របស់កសិករ**

ផលិតកម្មកូនត្រីទីឡាព្យ៉ាឆ្នាំ .................... ខែ .................

| ឈ្មោះអ្នក | ចំនួន | | ចំនួនស្រះ | បរិមាណជីដាក់ស្រះ (គ.ក្រ) | | | | | បរិមាណចំណី (គ.ក្រ) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផលិតកូនត្រី | ឈ្មោល | ញី | សរុប | លាមកគោ | ល.ជ្រូក | ជីបៃតង | អ៊ុយរ៉េ | ដេអាប៉េ | ចក | កាកបន្លែ | កន្ទក់ | ផ្សេងៗ |
| | | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័តិមានអំពី ៖ បញ្ហាកើតមានឡើង ការលំបាក ការរីកចំរើន អនុសាសន៍ សំណូមពរ | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័តិមានអំពី ៖ បញ្ហាកើតមានឡើង ការលំបាក ការរីកចំរើន អនុសាសន៍ សំណូមពរ | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័តិមានអំពី ៖ បញ្ហាកើតមានឡើង ការលំបាក ការរីកចំរើន អនុសាសន៍ សំណូមពរ | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| **សរុប** | | | | | | | | | | | | |

**តារាងប្រមូលទិន្នន័យប្រចាំខែ សកម្មភាពបំប៉នកូនត្រី របស់កសិករ**

ផលិតកម្មកូនត្រីទីឡាព្យ៉ាឆ្នាំ .................... ខែ .................

| ឈ្មោះអ្នក | ចំនួនកូនត្រី | | ចំនួនស្រះ | បរិមាណជីដាក់ស្រះ (គ.ក្រ) | | | | | បរិមាណចំណី (គ.ក្រ) | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ផលិតកូនត្រី | ប៉ាន់ប្រមាណ | | | លាមកគោ | ល.ជ្រូក | ជីបៃតង | អ៊ុយរ៉េ | ដេអាប៉េ | ចក | កាកបន្លែ | កន្ទក់ | ផ្សេងៗ |
| | ចំនួន | ស.ម | សរុប | | | | | | | | | |
| | | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័តិមានអំពី ៖ បញ្ហាកើតមានឡើង ការលំបាក ការរីកចំរើន អនុសាសន៍ សំណូមពរ | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័តិមានអំពី ៖ បញ្ហាកើតមានឡើង ការលំបាក ការរីកចំរើន អនុសាសន៍ សំណូមពរ | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| | | | ផ្នែកនេះសម្រាប់ប្រមូលព័តិមានអំពី ៖ បញ្ហាកើតមានឡើង ការលំបាក ការរីកចំរើន អនុសាសន៍ សំណូមពរ | | | | | | | | | |
| | | | | | | | | | | | | |
| | | | | | | | | | | | | |
| **សរុប** | | | | | | | | | | | | |

**តារាងប្រមូលទិន្នន័យបរិមាណកូនត្រី ដែលចាប់បានពីស្រះបង្ហាត់**

ផលិតកម្មកូនត្រីទីឡាព្យ៉ាឆ្នាំ .................. ខែ ................. ស្រះបង្កាត់លេខ .............. ផ្ទៃស្រះ ..................ម$^{២}$

ថ្ងៃ ខែ ឆ្នាំ ដាក់ត្រីមេពូជបង្កាត់ ................................ ឈ្មោល .................. ក្បាល ញី .....................ក្បាល

| ថ្ងៃ ខែ ឆ្នាំ | ទំហំតូច | | ទំហំមធ្យម | | ទំហំធំ | | សរុប | ផ្សេងៗ |
|---|---|---|---|---|---|---|---|---|
| ចាប់កូនត្រី | ក្បាល | ស.ម | ក្បាល | ស.ម | ក្បាល | ស.ម | ក្បាល | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| សរុប | | | | | | | | |